ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ជំនាញជួសជុលកង់



## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៣០៦៧ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅ "ជំនាញជួសជុលកង់"

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ៨៤អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ២០០៥-២០០៩

-យោងសេចក្តីណែនាំលេខ ០៣ អយក.សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

-យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៣

-យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣

-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

### សម្រេច

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ "ជំនាញជួសជុលកង់" ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់អង្គការ អប់រំពិភពលោកសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀន និងរៀនកម្មវិធីបំណិនជីវិត នៅតាមអនុវិទ្យាល័យ ។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- កាលប្បវត្តិ
- ឯកសារ-អកស.

## គណៈកម្មការអភិវឌ្ឍសៀវភៅ
## "ជំនាញជួសជុលកង់"

### គណៈកម្មការនិពន្ធ និងរៀបរៀង

១. លោក អ៊ុល រុន
២. លោក អេង សុខ
៣. លោក វីលៀម វ៉ាន់ឌឺវ៉ាល់

### គណៈកម្មការកែសម្រួល

១. លោក ឈុំ វណ្ណធន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល

### គណៈកម្មការពិនិត្យ

១. លោក ព្រំ វិបុល
២. លោកស្រី ឃឹម ឃីហ៊ុប

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា.................................................................................................... ក

វត្ថុបំណងរួម.................................................................................................... ខ

ការត្រៀមលក្ខណៈមុនពេលបង្រៀន.................................................................. ខ

ខ្លឹមសារសង្ខេប.................................................................................................. គ

មេរៀនទី ១: ផ្នែកនីមួយៗនៃតួកង់.......................................................... ១

មេរៀនទី ២: របៀបប៉ះកង់................................................................... ៦

មេរៀនទី ៣: របៀបជួសជុលដុំមុខ.......................................................... ១០

មេរៀនទី ៤: របៀបជួសជុលដុំកណ្ដាល.................................................... ១៤

មេរៀនទី ៥: របៀបជួសជុលដុំក្រោយ..................................................... ១៨

មេរៀនទី ៦: របៀបជួសជុលដំឡាប់ក....................................................... ២២

មេរៀនទី ៧: របៀបដោះកាំ និង ដំឡើងកាំ............................................... ២៦

មេរៀនទី ៨: របៀបរឹតក្បាលកាំ.............................................................. ៣០

មេរៀនទី ៩: របៀបជួសជុល ហ្វ្រាំងមុខ-ក្រោយ......................................... ៣៤

មេរៀនទី ១០: របៀបដំឡើងតួកង់......................................................... ៣៨

# អារម្ភកថា

វិស័យអប់រំជាវិស័យគន្លឹះមួយ រួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញខ្ពស់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជននិងកីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិតសម្រាប់អនុវត្តន៍នៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលនឹងផ្តល់ ឲ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងពង្រឹងជំនាញផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិន ចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

កង់មានសារៈសំខាន់ណាស់ ព្រោះប្រជាជនទូទៅប្រើប្រាស់កង់ជាមធ្យោបាយដឹកជញ្ជូន សម្រាប់តម្រូវការផ្សេងៗនៅក្នុងជីវភាពរស់នៅ។ ឧទាហរណ៍ កុមារជិះកង់ទៅសាលារៀន ដែលអាចកាត់បន្ថយការចំណាយពេលច្រើន ក្នុងការធ្វើដំណើរ និងបង្កើនការសិក្សាអប់រំដល់កុមារក្នុងតំបន់ ដាច់ស្រយាល។ ការប្រើប្រាស់កង់សម្រាប់ដឹកទឹក ដឹកអុស (សម្រាប់ចំអិនអាហារ) ជាមធ្យោបាយដឹកជញ្ជូនរហ័ស និងជួយសម្រាលកម្លាំង ដែលអាចបង្កើនការថែរក្សាសុខភាព។ កង់ប្រើប្រាស់សម្រាប់ដឹកទំនិញទៅកាន់ទីផ្សារជិតៗ ដែលចូលរួមក្នុងការបង្កើនសេដ្ឋកិច្ចមូលដ្ឋាន និងជាពិសេសនោះកង់គឺជាមធ្យោបាយមួយ ដែលកុមារចូលចិត្តជិះជាការកំសាន្ត។

ដូច្នេះកង់គឺជាមធ្យោបាយដឹកជញ្ជូនមួយបែប ដែលចាំបាច់ណាស់ចំពោះប្រជាជនភាគច្រើននៅទីជនបទ ប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាមួយចំនួន នៅក្នុងជីវិតប្រចាំថ្ងៃ។ នេះជាកត្តាមួយដែលឆ្លុះបញ្ចាំង ពីភាពចាំបាច់ក្នុងការបង្រៀនឱ្យកុមារចេះពីរបៀបជួសជុល មានបំណិនប្រសប់ និង មានឥរិយាបថស្រឡាញ់ ថែរក្សា ដោយអាចធ្វើជាមុខរបរអាជីពបានទៀតផង។ នៅក្នុងម៉ុឌុលនេះ កុមារនឹងរៀនអំពីរបៀបជួសជុលកង់ខ្មែរ តាមរយៈការអនុវត្តបង្ហាញជាគំរូពីគ្រូ បន្ទាប់មក គឺការអនុវត្តផ្ទាល់ ដោយការធ្វើការងារជាក្រុម។ តាមរយៈការសិក្សាលើជំនាញជួសជុលកង់នេះ សិស្សទទួលបាននូវបំណិនផ្សេងៗទៀតដូចជា ការសហការជាក្រុម ការសង្កេត ការបង្កើនទំនុកចិត្ត ការមានអារម្មណ៍ល្អចំពោះការសិក្សាអប់រំ តាមរយៈវិធីសាស្ត្របែបអនុវត្តជាក់ស្តែង ការងារក្រុម ការបំផុសគំនិត ការបង្កើតផែនទីគំនិត និងករណីសិក្សាជាដើម។ ជាពិសេសនោះ គឺការបណ្តុះនូវគំនិតការគិតដោយ វិភាគ នឹងឈានទៅរកការច្នៃប្រឌិតអភិវឌ្ឍ ម៉ូតកង់ និងបច្ចេកទេស

កង់របស់ខ្មែរនាពេលអនាគត ទន្ទឹមនឹងការចេះជួសជុលដោយខ្លួនឯងនៅពេលដែលកង់របស់ខ្លួនខូច ដោយមិនចំណាយថវិកាផ្ទាល់ខ្លួន ឬអាចបង្កើតទៅជាមុខរបរនៅក្នុងសហគមន៍របស់ពួកគេ។





## ១. វត្ថុបំណងរួម

បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព។ *(គោលនយោបាយបំណិនជីវិត២០០៦)។ វត្ថុបំណងលម្អិតនៃម៉ូឌុលនេះគឺ :*

- ធ្វើតាមជំហាន និងតាមលំដាប់លំដោយនៃរបៀបជួសជុលកង់ ផ្នែកប៉ះកង់ ជួសជុលដុំមុខ-កណ្ដាល និងក្រោយ ជួសជុលដំឡាប់ក របៀបដោះកាំ និងរឹតកាំ ជួសជុល ហ្វ្រាំងមុខ-ក្រោយ និងការដំឡើងតួកង់បានត្រឹមត្រូវ
- អនុវត្តបាន និងមានបំណិនប្រសប់ពីរបៀបជួសជុលកង់ ផ្នែកប៉ះកង់ ជួសជុលដុំមុខ-កណ្ដាល និងក្រោយជួសជុលដំឡាប់ក របៀបដោះកាំ និងរឹតកាំ ជួសជុល ហ្វ្រាំងមុខ-ក្រោយ និងការដំឡើង តួកង់បានត្រឹមត្រូវ
- បង្ហាញពីរបៀបប្រើប្រាស់ និងមានទម្លាប់ថេះថែទាំឱ្យបានយូរអង្វែង
- យកបំណិននេះទៅផ្សារភ្ជាប់ជីវភាពរស់នៅ និងធ្វើជាអាជីព។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះចែកចេញជាច្រើនផ្នែកផ្សេងៗគ្នា ហើយមានគោលបំណងខុសៗគ្នា។ ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស ជាដំណាក់កាលត្រៀមរបស់គ្រូ។ ព័ត៌មានទាក់ទងនឹងការបង្រៀន និងរៀន ពិសេសមេរៀន ត្រូវបានគ្រូត្រៀមទុកជាមុន។

### ● សម្ភារឧបទេស

ផ្នែកនេះផ្ដល់នូវសេចក្ដីសង្ខេបស្ដីអំពីសម្ភារឧបទេស ដែលភាគច្រើនជាសម្ភារៈមូលដ្ឋាន ដូចជា ប៊ិក ឬ ក្រដាស។ សម្ភារៈផ្សេងទៀតនៅក្នុងមេរៀននេះនឹងត្រូវផ្ដល់ឱ្យសិស្សសម្រាប់អនុវត្ត តាមរយៈឯកសារ សម្រាប់សិស្ស ដែលបានភ្ជាប់នៅក្នុងម៉ូឌុលនេះ។

### ● វត្ថុបំណង

ផ្ដល់នូវឃ្លាបញ្ជាក់នូវអ្វីនឹងត្រូវសម្រេចបាន និងវាយតម្លៃនៅខាងចុងមេរៀន។ ឃ្លាទាំងនេះទាក់ទងនឹង គោលដៅរួមនៃបំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិ ព្រមទាំងកំណត់នៅក្នុង*បំណិនមូលដ្ឋាន ការសិក្សាជំនួញ បំណិនសេដ្ឋកិច្ច និងបំណិនអាជីពងាយៗ។*

### ● សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ

ខាងក្រោមនេះ ជាសញ្ញាសម្គាល់សកម្មភាពងាយៗដើម្បីឱ្យគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀន និងរៀន។

- ធ្វើសកម្មភាព ៖ គ្រូចាំបាច់ត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន
- សរសេរ ៖ ពេលខ្លះត្រូវការឱ្យគ្រូសរសេរនៅលើក្ដារខៀន
- សួរ ៖ មានសំណួរ ដែលត្រូវសួរទៅកាន់សិស្ស
- ពន្យល់ ៖ ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា ៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្តីផ្តើមដែលយើងព្យាយាមផ្សារភ្ជាប់ ទៅនឹងចំណេះដឹងដែលសិស្សមានស្រាប់ ឬរំឭកមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗ ដោយផ្អែកលើវិធីសាស្រ្តបង្រៀនបែបការងារគម្រោង(ចុះស្រាវជ្រាវ ប្រមូលព័ត៌មានសម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...។) និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ យើងអាចធានាបានថា រាល់លទ្ធផលនៃការសិក្សារបស់យើងគឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។

## ៣. ខ្លឹមសារសង្ខេប

ខ្លឹមសារសង្ខេបត្រូវបានផ្តល់ជូនឱ្យគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាខ្លឹមសារសង្ខេបរួមទាំង ១០ មេរៀនដែលនៅក្នុងម៉ូឌុលបំណិនជីវិតនេះ:

| ចំណងជើងមេរៀន | រយៈពេល | វត្ថុបំណង | ទំព័រ |
|---|---|---|---|
| ១. ផ្នែកនីមួយៗ នៃគូកង់ | ២ ម៉ោង | សិស្សនឹងសិក្សាដើម្បីស្គាល់អំពីផ្នែកទាំងបីនៃកង់រួមមាន ផ្នែកមុខ កណ្តាល និងក្រោយ និងឧបករណ៍ជួសជុលកង់តាមរយៈការពិភាក្សាជាក្រុម។ | ១ |
| ២. របៀបប៉ះកង់ | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងការប៉ះកង់។ គ្រូអនុវត្តជាគំរូ សិស្សអនុវត្តតាម និងសង្កេត។ | ៦ |
| ៣. របៀបជួសជុលដុំមុខ | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងរបៀបជួសជុលដុំមុខ។ គ្រូអនុវត្តជាគំរូ សិស្សអនុវត្តតាម និង សង្កេត។ | ១០ |
| ៤. របៀបជួសជុលដុំកណ្តាល | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងរបៀបជួសជុលដុំកណ្តាល។ គ្រូអនុវត្តជាគំរូ សិស្សអនុវត្តតាម និងសង្កេត។ | ១៤ |
| ៥. របៀបជួសជុលដុំក្រោយ | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងរបៀបជួសជុលដុំក្រោយ។ គ្រូអនុវត្តជាគំរូ សិស្សអនុវត្តតាម និងសង្កេត។ | ១៨ |
| ៦. របៀបជួសជុលដំឡាប់ក | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងរបៀបជួសជុលដំឡាប់ក។ គ្រូអនុវត្តជាគំរូ សិស្សអនុវត្តតាម និង សង្កេត។ | ២២ |
| ៧. របៀបដោះកាំ និង ដំឡើងកាំ | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងរបៀបដោះកាំ និងរៀបកាំ។ គ្រូអនុវត្តជាគំរូ សិស្សអនុវត្តតាម និងសង្កេត។ | ២៦ |

| | | | |
|---|---|---|---|
| ៨. របៀបរិតក្បាលកាំ | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងរបៀបរិតក្បាលកាំ។ គ្រូអនុវត្តជាគំរូ សិស្ស អនុវត្តតាម និងសង្កេត។ | ៣០ |
| ៩. របៀបជួសជុល ហ្វ្រាំងមុខ - ក្រោយ | ២ ម៉ោង | សិស្សធ្វើការជាក្រុមដើម្បីបង្ហាញពីចំណេះដឹងទាក់ទងនឹងរបៀបជួសជុល ហ្វ្រាំងមុខ-ក្រោយ។ គ្រូអនុវត្តជាគំរូ សិស្សអនុវត្តតាម និងសង្កេត។ | ៣៤ |
| ១០. របៀបដំឡើងតួកង់ | ២ ម៉ោង | សិស្សសហការគ្នាដំឡើងតួកង់ទាំងមូលបន្ទាប់ពីបានសិក្សារយៈពេល៩សប្តាហ៍កន្លងមក។ | ៣៨ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរ ដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុងម៉ូឌុល ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្ស ដោយគ្រូជាអ្នកសង្កេត ផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្សនេះ យើងគិតពិន្ទុ ៥០ ស្មើទៅនឹងមុខវិជ្ជាមួយចំនួនផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្ដាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។ ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបថសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្តល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: ផ្នែកនីមួយៗនៃតួកង់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- កង់មួយគ្រឿង
- ឧបករណ៍ប្រើប្រាស់សម្រាប់ជួសជុលកង់
- គ្រឿងបន្លាស់សម្រាប់ផ្លាស់ប្ដូរ
- ចំណិតក្រដាសសម្រាប់សិស្សសរសេរឈ្មោះផ្នែកផ្សេងៗនៃកង់
- ស្កុតក្រដាស

☼ **វត្ថុបំណង**

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- ប្រាប់ពីឈ្មោះពីផ្នែកនីមួយៗនៃតួកង់បានត្រឹមត្រូវ
- បង្ហាញពីឧបករណ៍ប្រើប្រាស់សម្រាប់ជួសជុលកង់

**សេចក្ដីផ្ដើម (ល្បែង: តើខ្ញុំជាអ្វី?)** 🕑 ១០ នាទី

✏ សរសេរចំណងជើងម៉ូឌុលនៅលើក្ដារខៀន "ការជួសជុលកង់"។

✋ ឱ្យសិស្សគិតអំពីអ្វីមួយដែលពាក់ព័ន្ធនឹងប្រធានបទ បន្ទាប់មក ឱ្យសិស្សស្ម័គ្រចិត្តឡើងធ្វើកាយវិការ បង្ហាញដល់សិស្សនៅក្នុងថ្នាក់។ សិស្សទាំងឡាយត្រូវទស្សន៍ទាយកាយវិការរបស់សិស្សនោះ។ បើសិនអ្នកណាម្នាក់ទស្សន៍ទាយត្រូវ សិស្សស្ម័គ្រចិត្តត្រូវលើកមេដៃឡើងលើ ដើម្បីផ្ដល់ជាសញ្ញាថាត្រឹមត្រូវ។ ក្រោយមកឱ្យសិស្សដែលស្ម័គ្រចិត្តនោះសរសេរពាក្យ ឬសកម្មភាពដែលគេបានសម្ដែងនៅលើក្ដារខៀន។

## សកម្មភាពសំខាន់។ ⏲ ៦៥ នាទី

✋ រៀបចំកង់មួយគ្រឿងដាក់នៅខាងមុខសិស្ស ក្បែរក្ដារខៀន។

👄 ចែកសិស្សជា៤ក្រុម ដែលមានសមាជិក ៥នាក់ក្នុងមួយក្រុម។ ប្រាប់ឱ្យសិស្សរាប់លេខពី ១ដល់៤ បន្ទាប់មកត្រូវចូលក្រុមតាមលេខ។ នៅក្នុងក្រុមនីមួយៗត្រូវមានប្រធាន និងអនុប្រធាន។ ក្រុមទី១ ពិភាក្សាលើសំណួរៈ តើផ្នែកមុខនៃកង់មានអ្វីខ្លះ? ក្រុមទី ២ៈ តើផ្នែកកណ្ដាលនៃកង់មានអ្វីខ្លះ? ក្រុមទី ៣ៈ តើផ្នែកក្រោយនៃកង់មានអ្វីខ្លះ? ក្រុមទី ៤ៈ តើឧបករណ៍ជួសជុលកង់មាន អ្វីខ្លះ? សិស្សពិភាក្សាគ្នាតាមក្រុម ហើយកត់ត្រាចម្លើយយកមកបិទលើផ្នែកនីមួយៗ នៃតួកង់។

👄 បន្ទាប់ពីក្រុមទាំង៤ បានបិទស្លាកនៅតាមផ្នែកផ្សេងៗនៃកង់រួចហើយ គ្រូអាចឱ្យសិស្សក្រុមនីមួយៗឡើងចង្អុលបង្ហាញ ព្រមទាំងអានពាក្យនោះឱ្យបានច្បាស់ និងត្រឹមត្រូវ។

✏ គ្រូសរសេរឈ្មោះផ្នែកនីមួយៗនៃកង់នៅលើក្ដារខៀន និងសួរបញ្ជាក់បន្ថែមបើសិនជាមាន ផ្នែកខ្លះសិស្សប្រាប់មិនអស់។

✋ ចែកឯកសារអំពីរូបភាពកង់ ហើយឱ្យសិស្សបំពេញឈ្មោះ នៅពេលគ្រូបូកសរុបចប់។

ចម្លើយរំពឹងទុក៖

(ក្រុមទី១)ផ្នែកមុខនៃកង់៖

- កង់មុខ៖ សំបក ខ្នង កាំ វ៉ាល់ ដុំ ភ្លៅ គម្របភក់ ដែកកាង តង្កៀបហ្វ្រាំងមុខ
- ជំពាស់មុខ៖ ជំពាស់មុខ ដំឡាប់កលើ-ក្រោម
- ដៃ៖ ដៃចង្កូត ស្រោមដៃ កណ្ដឹង ដៃ ហ្វ្រាំងមុខ-ក្រោយ ខ្សែ ហ្វ្រាំងមុខ-ក្រោយ កសេះ ខ្ចៅកូនជញ្ជីង ក្រចាប់ដៃ

(ក្រុមទី២)ផ្នែកកណ្ដាលនៃកង់៖

- ទូក៖ ទូកបញ្ឈរ ទូកផ្ដេកលើ ទូកផ្ដេកក្រោម កែប កកែប ក្រចាប់កកែប
- ដុំកណ្ដាល៖ ដុំកណ្ដាល ខ្ចៅកាស់ ភ្លៅ ជង្គង់ឆ្វេង-ស្ដាំ កន្លាស់ឈ្នាន់ ថាស ឈ្នាន់ឆ្វេង-ស្ដាំ គម្របថាស ច្រវ៉ាក់

(ក្រុមទី៣)ផ្នែកក្រោយនៃកង់៖

- កង់ក្រោយ៖ សំបក ខ្នង កាំ វ៉ាល់ ដុំ ភ្លៅ ជន្ទល់ លីប
- គម្របភក់ ដែកកាង តង្កៀបហ្វាំងក្រោយ រាន ក្រចាប់រាន ឬក្រចាប់កកែប

(ក្រុមទី៤)ឧបករណ៍ជួសជុលកង់៖

● សោមាត់ពីលេខ៨-១៨ ដង្កាប់មាត់ក្រពើ ដង្កាប់អូតូម៉ាទិក ម៉ាឡេត អង្គុំដុំកណ្ដាល អង្គុំធម្មតា សោគាស់ដែកប៉ុងតួ ដែកចុងស្រួច ញញួរ ទួរណឺវីស កាវ បំណះ ផ្លែរណា ឬស្សីមូល ដែកទីប កាធុនទឹក សោរឹតកាំ កន្សែងឬសាច់ កំណាត់ខ្លាញ់គោ ស្នប់សប់កង់។

## បញ្ចប់មេរៀន

🕑 ១៥ នាទី

- ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ឈ្មោះផ្នែកនីមួយៗនៃតួកង់ឡើងវិញ។

- នៅសប្តាហ៍ក្រោយយើងសិក្សាពីរបៀបប៉ះកង់ សូមប្អូនៗទៅសិក្សាស្រាវជ្រាវនៅផ្ទះជាងជួសជុលកង់ កត់ត្រាសកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្តីណែនាំសម្រាប់គ្រូ

- ចំពោះសកម្មភាពលេងល្បែង គ្រូអាចឱ្យសិស្សសម្តែងសកម្មភាពគ្រាប់តាមអ្វី មួយដែលពាក់ព័ន្ធ នឹងប្រធានបទ។

- ក្រោយពេលសិក្សាមេរៀននីមួយៗចប់ គ្រូគួរដាក់កិច្ចការឱ្យសិស្សសិក្សាស្រាវជ្រាវជាមុន។ កិច្ចការនេះទាក់ទងទៅនឹងមេរៀន ដែលត្រូវសិក្សាបន្ទាប់ពីព្រោះតាមបទពិសោធន៍កន្លងមក បើសិនគ្រូមិនបានធ្វើបែបនេះទេ សិស្សពុំមានចំណេះដឹង និងបំណិនគ្រប់គ្រាន់ក្នុងការសិក្សាឱ្យចេះរយៈពេល ២ម៉ោងបាននោះទេ។







# មេរៀនទី ២: រៀបប៉ះកង់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

កង់ ដង្កាប់មាត់ក្រពើ សោមាត់លេខ១០-១១ ដែកគាស់ កាធុនទឹក ឈើចាក់ធ្មេញចុងស្រួច កន្សែង ឬសាច់កំណាត់ ឬស្ប៊ីមូលប៉ុនដងស្ទប់ប្រវែង២តឹក ផ្លែរណាអារដែក បំណះ ជ័រការ៉ាល់។

*ចំណាំ៖ សម្ភារៈ និង ឧបករណ៍ត្រូវមាន៥ សម្រាប់ (គ្រូ ១ សម្រាប់, សិស្ស៤ក្រុម ៤សម្រាប់)។*

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- ប្រាប់ពីជំហាន និងលំនាំតាមលំដាប់លំដោយពីរបៀបប៉ះកង់បានត្រឹមត្រូវ
- អនុវត្តបាន និងមានបំណិនប្រសប់ពីរបៀបប៉ះកង់បានត្រឹមត្រូវ
- មានទម្លាប់ និងយល់ពីរបៀបប្រើប្រាស់ ការថែទាំបានល្អយូរអង្វែង
- យកបំណិនទៅផ្សារភ្ជាប់ជីវភាពរស់នៅជាក់ស្តែង និងធ្វើជាអាជីព

## សេចក្តីផ្តើម

🕑 ១០ នាទី

ឱ្យសិស្សគិតរយៈពេល២ឬ៣នាទីអំពីសំណួរៈ នៅពេលប្អូនៗធ្លាយកង់យកទៅឱ្យជាងកង់ប៉ះ តើប្អូនៗសង្កេតឃើញជាងកង់ធ្វើសកម្មភាពដូចម្តេចខ្លះ?

✎ គ្រូគួរសរសេរសំណួរនៅលើក្តារខៀនក្នុងរង្វង់ បែបជាផែនទីគំនិត ដូចរូបភាពខាងក្រោម។

គ្រូដើរទៅក្បែរសិស្ស ហើយលើកឧទាហរណ៍ល្អមួយ ហើយសរសេរចម្លើយក្បែរសញ្ញាព្រួញដើម្បីជួយសិស្សឱ្យ ងាយស្រួលនឹងស្វែងរក។




◈ តើគេប្រើឧបករណ៍អ្វីខ្លះក្នុងការប៉ះពោះវៀនកង់នេះ?

## សកម្មភាពសំខាន់។

⏱ ៦៥ នាទី

ចែកសិស្សជា ៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក ៥នាក់។ គ្រូនឹងធ្វើបង្ហាញពីការប៉ះកង់ ទន្ទឹមនឹងនោះសមាជិកម្នាក់នៅក្នុងក្រុមនីមួយៗត្រូវអនុវត្តតាម ហើយសមាជិកក្នុងក្រុមត្រូវសង្កេតលើគ្រប់សកម្មភាព។

គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេមកអនុវត្តក្នុងការសិក្សានេះផងដែរ ។

តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

គ្រូចាប់ផ្តើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តំណាងក្រុមនីមួយៗអនុវត្តតាម អ្នកដែលនៅសល់ ក្នុងក្រុមធ្វើការសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយនៅលើឯកសារចែកឱ្យ។ សកម្មភាពទាំងឡាយត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖

- ដោះចេញ៖ ផ្តេកកង់ឱ្យដេកយកសោមាត់លេខ ១០-១១ ឬដង្កាប់មកដោះត្រង់គល់វ៉ាល់។ យកសោគាស់៣មកគាស់សំបកម្ខាងចេញពីខ្នង រួចទាញយកពោះវៀនចេញ។



- ជួសជុល៖ ពិនិត្យមើលសំបកខាងក្រៅ លូកដៃស្ទាបច្បូតក្នុងសំបក រកមើលបន្លា ឬដែក គោលដែលមុតជាប់នឹងសំបក បើឃើញមានត្រូវយកចេញ។ សប់ពោះវៀនកង់ឱ្យតឹង ល្មម រួចដាក់ក្នុងកាធុនទឹក រកមើលកន្លែងមុតឬធ្លាយ ពេលឃើញហើយត្រូវយកឈើ ចាក់ធ្មេញចុងស្រួចមកដោតចំណាំ។ ជូតពោះវៀនឱ្យស្ងួតទឹក ត្រង់កន្លែងមុតឬធ្លាយ ដកឈើដោតចេញ យកផ្លែរណាអារដែកមកកោសបន្តើរៗជុំវិញកន្លែងមុតទំហំប៉ុន បំណះ យកជ័រការមកលាបស្តើងៗត្រង់កន្លែងកោស ទុកឱ្យស្ងួត បន្តិចយកបំណះ មកបិទពីលើ រួចយកឬស្សីមូលមួយ ទៀតមកជំពីលើបំណះតិចៗឱ្យសព្វ។ ក្រោយពី ប៉ះរួច ហើយសប់ពោះវៀនកង់នោះ ឱ្យតឹង ល្មម យកទៅដាក់ក្នុងកាធុន ទឹកម្តងទៀត ត្រង់កន្លែងប៉ះរួចពិនិត្យមើលក្រែងមិនជិត។



● បញ្ចូលទៅវិញ៖ បញ្ចូលពោះវៀនក្នុង សំបក ដោយដាក់ ត្រង់គល់វ៉ាល់មុន រួចបញ្ចូលសំបកទៅវិញ សប់ខ្យល់ បញ្ចូលឱ្យតឹងល្មម រិតខ្ចៅត្រង់គល់វ៉ាល់។



បើសិនជាមានពេលវេលានៅសល់ គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកផ្សេងៗក្នុងក្រុមជាអ្នកអនុវត្ត។

**បញ្ចប់មេរៀន** ១៥ នាទី

ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ ពីរបៀបបោះកង់តាមលំដាប់លំដោយឡើងវិញ។

នៅសប្តាហ៍ក្រោយយើងសិក្សាពីរបៀបជួសជុលជុំមុខ សូមប្អូនៗទៅសិក្សាស្រាវជ្រាវនៅផ្ទះជាងជួសជុលកង់ កត់ត្រាសកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្តីណែនាំគ្រូ

● នៅពេលសិស្សអនុវត្តកោសបន្ទើរលើពោះវៀនកង់ គ្រូត្រូវរកពោះវៀនចាស់ដែលគេចោល យកមកឱ្យសិស្សអនុវត្ត មិនមែនប្រើប្រាស់ពោះវៀនកង់របស់សិស្សនោះទេ។

● នៅក្នុងផ្នែក "បញ្ចប់មេរៀន" គ្រូឱ្យសិស្សរៀបរាប់សកម្មភាពសិក្សាឡើងវិញ បន្តរៀងគ្នា ពីក្រុមមួយទៅក្រុមមួយ មិនមែនឱ្យក្រុមនីមួយៗរៀបរាប់គ្រប់សកម្មភាព តាមលំដាប់ លំដោយនោះទេ។

● នៅចុងបញ្ចប់មេរៀននីមួយៗ គ្រូតែងតែឱ្យសិស្សទៅសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះ។ សិស្ស មួយ ចំនួនអាចធ្វើការសិក្សាបានតាមរយៈការសាកសួរឪពុក ម្តាយ បងប្អូន ឬជាមួយជាងនៅក្នុងសហគមន៍នោះ។ ក្នុងករណីចាំបាច់ គ្រូអាចឱ្យសិស្សខ្ចីសម្ភារៈជួសជុលដើម្បីទៅសិក្សានៅផ្ទះបាន ហើយនៅសប្តាហ៍ក្រោយក្នុងម៉ោងបំណិនជីវិតពួកគេត្រូវផ្តល់មកវិញ ប៉ុន្តែគ្រូត្រូវ គ្រប់គ្រងការខ្ចី នេះឱ្យបានល្អ ជៀសវាងការបាត់បង់។



សិស្សត្រូវដាក់ស្លាកឈ្មោះនៅផ្នែកផ្សេងៗនៃកង់ បន្ទាប់ពីការសួរបំផុសជាក្រុមធំ




សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជាគំរូ និងការអនុវត្តដោយសិស្សដទៃទៀត។



ការដោះចេញៈ ..............................................................................................................

..............................................................................................................................

..............................................................................................................................។

ការជួសជុលៈ ..............................................................................................................

..............................................................................................................................

..............................................................................................................................។

ការដាក់ចូលៈ ..............................................................................................................

..............................................................................................................................

..............................................................................................................................។

# មេរៀនទី ៣: របៀបជួសជុលដុំមុខ

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

កង់ សោមាត់លេខ ១៤-១៥ ដង្កាប់ស្វ័យប្រវត្តិ កន្សែងឬកំណាត់ទ្រាប់ដំឡាប់ ចាន គ្រាប់កង់មុខ ខ្លាញ់គោ ភ្លៅមុខ១សម្រាប់។

ចំណាំ៖ សម្ភារៈ និង ឧបករណ៍ត្រូវមាន៥ សម្រាប់ (គ្រូ ១ សម្រាប់ សិស្ស៤ក្រុម ៤សម្រាប់)។

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- បង្ហាញតាមលំដាប់លំដោយពីរបៀបជួសជុលដុំមុខ បានត្រឹមត្រូវ
- អនុវត្តបាន និងមានបំណិនប្រសប់ពីរបៀបជួសជុលដុំមុខ បានត្រឹមត្រូវ
- ប្រាប់ពីរបៀបប្រើប្រាស់ និងមានទម្លាប់ថែរថៃទាំឱ្យបានល្អ យូរអង្វែង
- អនុវត្តបំណិននេះផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្ដែង ឬធ្វើជាអាជីព

## សេចក្ដីផ្ដើម 🕑 ១0 នាទី

សួរសិស្សពីលទ្ធផលសិក្សាស្រាវជ្រាវពីសប្ដាហ៍មុន ពីរបៀបជួសជុលដុំមុខនៅក្នុង សហគមន៍របស់ពួកគេ។ ដើម្បីរំឭក ឬចង់ដឹងពីការយល់ដឹងរបស់ពួកគេពីផ្នែកជួសជុលដុំ មុខនេះ គ្រូត្រូវលេងល្បែងមួយដែលមាន ឈ្មោះថា "ស្ដាប់ និងនិយាយ"។

ឱ្យសិស្សបង្កើតក្រុមដែលមានសមាជិកពី៥ទៅ៦នាក់។ ពួកគេត្រូវប្រាប់ពីអ្វីដែលបានដឹងពីការ ជួសជុលដុំមុខ ឬពីបទពិសោធន៍ដែលពួកគេបានជួបប្រទះ។ សកម្មភាពនេះអាចធ្វើរយៈពេល ៣0វិនាទី។ គ្រូផ្ដល់ពេល ១នាទី ឱ្យពួកគេគិតពីប្រធានបទនេះដោយស្ងៀមស្ងាត់។ បើសិន អ្នកប្រាប់ថា "ចាប់ផ្ដើម" សិស្សក្នុងក្រុមទាំងអស់ត្រូវចាប់ផ្ដើម ប្រាប់គ្នាទៅវិញទៅមកអំពីអ្វី ដែលខ្លួនបានដឹងក្នុងពេលតែមួយ។ នេះមានន័យថាសិស្សគ្រប់គ្នាកំពុងនិយាយក្នុងពេល ដំណាលគ្នា។ គោលបំណងនៃល្បែងនេះគឺថា ចង់ឱ្យសិស្សនិយាយ ប៉ុន្តែទន្ទឹមនឹងពេលជាមួយ គ្នានោះ គេត្រូវព្យាយាមស្ដាប់អ្វីដែលអ្នកដទៃកំពុងនិយាយផងដែរ។ នៅទីបញ្ចប់អនុញ្ញាតឱ្យសិស្សនិយាយពីអ្វីដែលពួកគេបានឮពីសិស្សដទៃទៀត។

## សកម្មភាពសំខាន់។

🕐 ៦៥ នាទី

យើងនឹងធ្វើការជា៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ គ្រូនឹងអនុវត្តបង្ហាញពីការជួសជុលដុំមុខ ទន្ទឹមនឹងនោះ សមាជិកម្នាក់តំណាងឱ្យក្រុមនីមួយៗ ត្រូវអនុវត្តតាម ហើយសមាជិកក្នុងក្រុមត្រូវសង្កេត កត់ត្រា លើគ្រប់សកម្មភាពលើឯកសារចែកឱ្យ។

គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេ មកអនុវត្តក្នុងការសិក្សានេះផងដែរ ។

តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?
គ្រូចាប់ផ្តើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តំណាងឱ្យក្រុមនីមួយៗ អនុវត្តតាមអ្នកដែលនៅសល់ធ្វើការសង្កេត។

សមាជិកក្រុមនីមួយៗសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយ។ សកម្មភាពទាំងឡាយ ត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖

- ដោះចេញ៖ ដាក់កង់បញ្ច្រាស យកសោមាត់លេខ ១៤-១៥ មកដោះកង់ចេញពីជំពាស់។ ដោះខ្មៅទប់ខាងចេញ ដោះខ្មៅកាស់ស្តើងចេញ យករ៉ងស្តើងចេញ និង ខ្មៅដំឡាប់ចេញ ផ្នែកម្ខាងទាំងអស់ ឬយកខ្មៅចេញទាំងអស់ពីភ្លៅ បើសិនដំឡាប់ខូច។ យកគ្រាប់ចេញ ពីក្នុងចានចេញទាំងសងខាង។ ជូតខ្មៅរ៉ង ដំឡាប់គ្រាប់ និងភ្លៅ ដែលដោះចេញទាំងអស់ឱ្យស្អាត រកមើលកន្លែងខូច បើខូចត្រង់ណាមួយ ត្រូវផ្លាស់ចេញ ចំពោះគ្រាប់ បើមានខូចត្រូវផ្លាស់ចេញទាំងអស់។





● ជួសជុល៖ ត្រូវមួលរឹតដំឡាប់ រ៉ង ស្ពើង និង ខ្ចៅរ៉ង ស្ពើងម្ខាងឱ្យងាប់ កុំឱ្យមួលចូលក្នុងបាន។ យកខ្លាញ់ គោ មកលាបក្នុងចានបន្តិច រៀប គ្រាប់ដាក់ចូលឱ្យពេញ ទាំងសង ខាង រួចយកខ្លាញ់គោមកលាប បន្ថែមឱ្យពេញក្នុងចាន។ ស៊កភ្លៅចូលទៅក្នុងដុំវិញ ខាងខ្ចៅងាប់ត្រូវនៅខាងស្តាំ ឬខាងចាស មួលខ្ចៅដំឡាប់ឲ្យបានតឹង តែអាចវិលភ្លៅបានដាក់រ៉ងស្ពើង ចូលនិងមួលខ្ចៅកាស់ស្ពើង ចូលឱ្យបានតឹង។

● ដាក់ចូល៖ យកកង់បញ្ចូលក្នុងជំពាស់វិញ ត្រូវដាក់ខាងខ្ចៅងាប់នៅខាងស្តាំ មួលខ្ចៅ ទប់ខាងចូលឱ្យតឹង ដោយស៊ីរ៉េខ្ទងកង់ឱ្យចំកណ្តាលជំពាស់ ជាការស្រេច។

បើសិនជាមានពេលវេលានៅសល់ គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកម្នាក់ៗ ក្នុងក្រុមជាអ្នកអនុវត្ត។

**បញ្ចប់មេរៀន** ១៥ នាទី

យកកង់ដែលជួសជុលដុំកង់មុខរួច មកដាក់តាំងបង្ហាញ

ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយ។

ពេលត្រឡប់ទៅផ្ទះវិញ ប្អូនត្រូវហ្វឹកហាត់ពីរបៀបជួសជុលដុំកង់មុខឱ្យបានស្ទាត់ជំនាញ។ នៅសប្តាហ៍ក្រោយយើងសិក្សាពីរបៀបជួសជុលដុំកណ្តាល សូមប្អូនៗទៅសិក្សាស្រាវជ្រាវនៅផ្ទះជាងជួសជុលកង់ កត់ត្រាពីសកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្តីណែនាំគ្រូ

● នៅក្នុងផ្នែក "បញ្ចប់មេរៀន" គ្រូឱ្យសិស្សរៀបរាប់សកម្មភាពសិក្សាឡើងវិញ បន្តរៀងគ្នា ពីក្រុមមួយទៅក្រុមមួយ មិនមែនឱ្យក្រុមនីមួយៗរៀបរាប់គ្រប់សកម្មភាព តាមលំដាប់ លំដោយនោះទេ។

● នៅចុងបញ្ចប់មេរៀននីមួយៗគ្រូតែងតែឱ្យសិស្សទៅសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះ។ សិស្ស មួយ ចំនួនអាចធ្វើការសិក្សាបានតាមរយៈការសាកសួរឪពុកម្តាយ បងប្អូន ឬជាមួយជាងនៅក្នុងសហគមន៍នោះ។ ក្នុងករណីចាំបាច់ គ្រូអាចឱ្យសិស្សខ្ចីសម្ភារៈជួសជុលដើម្បីទៅសិក្សានៅផ្ទះបាន ហើយនៅសប្តាហ៍ក្រោយក្នុងម៉ោងបំណិនជីវិតពួកគេត្រូវផ្តល់ត្រឡប់មកវិញ ប៉ុន្តែគ្រូត្រូវគ្រប់គ្រងការខ្ចី នេះឱ្យបានល្អ ជៀសវាងការបាត់បង់។

រូបភាពជុំមុខ សម្រាប់សិស្សដាក់ស្លាកឈ្មោះ ។



សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជាគំរូ និងការអនុវត្តដោយសិស្សដទៃទៀត ។

ការដោះចេញ: ..................................................................................................................

...................................................................................................................................

................................................................................................................................... ។

ការជួសជុល: ......................................................................................................................

...................................................................................................................................

................................................................................................................................... ។

ការដាក់ចូល: .....................................................................................................................

...................................................................................................................................

................................................................................................................................... ។

# មេរៀនទី ៤: របៀបជួសជុលដុំកណ្តាល

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

កង់ ញញួរ ដែកទីប៣២ប្រវែង២តឹក កន្ទាស់ឈ្នាន់ ដែល១០លីចុងស្រួចប្រវែង១តឹក ដែក៦លី ប្រវែង ៥ហ៊ុន ម៉ាឡេត អង្គំដោះចាន ដែកប៉ុងតួ ខ្លាញ់គោ សោមាត់លេខ១០-១១ ភ្លៅ គ្រាប់ ចាន ខ្វៅរ៉ង ដុំកណ្ដាល១សម្រាប់។

*ចំណាំ៖ សម្ភារៈ និង ឧបករណ៍ត្រូវមាន៥ សម្រាប់ (គ្រូ ១ សម្រាប់ សិស្ស៤ក្រុម ៤សម្រាប់)។*

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- បង្ហាញពីរបៀបជួសជុលដុំកណ្ដាល តាមលំដាប់លំដោយបានត្រឹមត្រូវ
- អនុវត្តបំណិនប្រសប់ពីរបៀបជួសជុលដុំកណ្ដាល បានត្រឹមត្រូវ
- ប្រាប់ពីរបៀបប្រើប្រាស់ និងមានទម្លាប់ថែៈថែទាំឱ្យបានល្អ យូរអង្វែង
- អនុវត្តបំណិននេះផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្ដែង ឬធ្វើជាអាជីព។

## សេចក្ដីផ្ដើម

🕑 ១០ នាទី

👄 ពិនិត្យកិច្ចការស្រាវជ្រាវរបស់សិស្ស ពីការជួសជុលដុំកណ្ដាលដែលគ្រូបានដាក់ឱ្យ។ ដើម្បី ចង់ដឹងពីលទ្ធផល គ្រូឱ្យសិស្សធ្វើការសម្ភាសគ្នា។ គ្រូបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម។ ក្រុមមួយ ជាអ្នកយកព័ត៌មាន និងក្រុមមួយទៀតជាអ្នកវិទ្យាសាស្ត្រល្បីល្បាញ។ ប្រាប់សិស្សដែលជាអ្នកយកព័ត៌មានថា អ្នកអាចធ្វើសម្ភាសអ្នកវិទ្យាសាស្ត្រ អំពីប្រធានបទរបស់អ្នក (សំណួរពាក់ព័ន្ធផ្នែកដុំកណ្ដាល និងសម្ភារៈជួសជុល)។ ពួកគេអាចសួរសំណួរពីរចំពោះអ្នក វិទ្យាសាស្ត្រម្នាក់ៗ បន្ទាប់មកអាចសួរអ្នកវិទ្យាសាស្ត្រផ្សេងៗទៀតឱ្យបានច្រើននាក់តាមដែលអាចធ្វើបានតែក្នុង រយៈពេល ២នាទីប៉ុណ្ណោះ។ មុននឹងចាប់ផ្ដើមសកម្មភាពនេះ ត្រូវទុកពេល ឱ្យអ្នកយកព័ត៌មានគិតពីសំណួរ ហើយអ្នកវិទ្យាសាស្ត្រគិតពីចំណេះដឹងពាក់ព័ន្ធនឹងប្រធានបទ។ បន្ទាប់ពីរយៈពេល២នាទីនៃការធ្វើសកម្មភាព ឱ្យសិស្ស ដែលជាអ្នកយកព័ត៌មានសរសេរ សំណួរនៅលើក្ដារខៀន ព្រមទាំងចម្លើយដែលទទួលបាន។

✋ ពិនិត្យមើលសំណួរ និងចម្លើយ ធ្វើការកោតសរសើរ និងកែតម្រូវទៅតាមការចាំបាច់។

## សកម្មភាពសំខាន់។

🕑 ៦៥ នាទី

យើងនឹងធ្វើការជា៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ គ្រូនឹងអនុវត្តបង្ហាញពីការជួសជុលជុំមុខ ទន្ទឹមនឹងនោះ សមាជិកម្នាក់តំណាងឱ្យក្រុមនីមួយៗត្រូវអនុវត្តតាម ហើយសមាជិកក្នុង ក្រុមត្រូវសង្កេត កត់ត្រា គ្រប់សកម្មភាពលើឯកសារចែកឱ្យ។

គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេមកអនុវត្តក្នុងការសិក្សានេះ ផងដែរ ។

តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

គ្រូចាប់ផ្តើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តំណាងឱ្យក្រុមនីមួយៗអនុវត្តតាម អ្នកដែលនៅសល់ ក្នុងក្រុមធ្វើការសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយ។ សកម្មភាពទាំងឡាយត្រូវ អនុវត្តដូចការរៀបរាប់ខាងក្រោម៖

● ដោះចេញ៖ ដាក់កង់បញ្ឈរ ដោះខ្ចៅកន្លាស់ឈ្នាន់យកដែកទីបមកទល់ឱ្យតឹងចំកន្លាស់ឈ្នាន់ យកញញួរវាយចុងកន្លាស់ឈ្នាន់ឱ្យខ្លាំង យកដែកមកវាយបញ្ចាល់កន្លាស់ឈ្នាន់ឱ្យចេញផុតពីចុងភ្លៅម្ខាង នៅចុងភ្លៅ ម្ខាងទៀតធ្វើដូចគ្នា។ យកដែកជ្រុងស្ពើងមកវាយ ដោះខ្ចៅរ៉ែងទប់ចានចេញ។ យកដែកចុងស្រួច ឬម៉ាឡេត ដោះខ្ចៅចាន រួចទាញយកភ្លៅចេញ និងយក គ្រាប់ចេញពីក្នុងចានទាំងសងខាង។



● ជួសជុល៖ ជូតក្នុងជុំភ្លៅ គ្រាប់ ចានឱ្យស្អាតរកមើល កន្លែងខូច បើខូចត្រង់ណាត្រូវផ្លាស់ ចេញ។ បើខូចចានខាងថាសត្រូវដោះនឹងអង្គំ ពេលដាក់ចូលវិញក៏ប្រើ អង្គំដែរត្រូវចាំ ថា ខ្ចៅចានខាងថាសត្រូវមួលបញ្ច្រាស។ បើខូចស្ពឺជុំជាប់នឹងទូកត្រូវយកដែក ប៉ុងគួ មកវាយបញ្ចជុំវិញត្រង់កន្លែងស្ពឺខូច។ គ្រាប់ខាងថាស ត្រូវរៀបនឹងភ្លៅ គ្រាប់ខាងឆ្វេងត្រូវរៀបនឹងចាន។



● ដាក់ចូល៖ ស៊កភ្លៅខាងឆ្វេងចូលទៅមុនដោយ ថ្នមៗ ឱ្យចេញផុត ចានខាងថាស កាន់ចុងភ្លៅ ខាងថាស ឱ្យតឹងត្រង់ មួលខ្ចៅចានខាងឆ្វេងឱ្យតឹងតែអាចវិលភ្លៅបានវាយឬមួល ខ្ចៅកាសចានឱ្យតឹង។ យកជង្គង់ដាក់ចូលក្នុងភ្លៅ បង្វិលមើល រន្ធកន្លាស់ឈ្នាន់ឱ្យស្រប តាមចំណិតចុងភ្លៅ ស៊ក កន្លាស់ ឈ្នាន់ឱ្យតឹង យកដែកទីបមកកល់ឱ្យតឹងចំរន្ធកន្លាស់ឈ្នាន់ រួចវាយឱ្យខ្លាំង។ នៅចុងកន្លាស់ឈ្នាន់ត្រូវដាក់វ៉ងស្តើង និង រឹតខ្ចៅទប់ឱ្យតឹង ជាការស្រេច។



បើសិនជាមានពេលវេលានៅសល់ គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកផ្សេងៗក្នុងក្រុមជាអ្នកអនុវត្ត។

**បញ្ចប់មេរៀន** ១៥ នាទី

យកកង់ដែលជួសជុលដុំកណ្តាលរួច មកដាក់តាំងបង្ហាញ។

ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយឡើងវិញ។

ពេលត្រឡប់ទៅផ្ទះវិញ ប្អូនត្រូវហ្វឹកហាត់ពីរបៀបជួសជុលដុំកណ្តាលឱ្យបានស្ទាត់ជំនាញ។ នៅសប្តាហ៍ក្រោយ យើងសិក្សាពីរបៀបជួសជុលដុំក្រោយ សូមប្អូនៗទៅសិក្សាស្រាវជ្រាវ នៅផ្ទះជាងជួសជុលកង់ កត់ត្រាពីសកម្មភាពតាម លំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្តីណែនាំគ្រូ

● នៅក្នុងផ្នែក "បញ្ចប់មេរៀន" គ្រូឱ្យសិស្សរៀបរាប់សកម្មភាពសិក្សាឡើងវិញ បន្តរៀងគ្នា ពីក្រុមមួយទៅក្រុមមួយ មិនមែនឱ្យក្រុមនីមួយៗរៀបរាប់គ្រប់សកម្មភាព តាមលំដាប់ លំដោយនោះទេ។

● នៅចុងបញ្ចប់មេរៀននីមួយៗគ្រូត្រូវតែឱ្យសិស្សទៅសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះ។ សិស្ស មួយ ចំនួនអាចធ្វើការសិក្សាបានតាមរយៈការសាកសួរឪពុកម្តាយ បងប្អូន ឬជាមួយជាងនៅក្នុងសហគមន៍នោះ។ ក្នុងករណីចាំបាច់ គ្រូអាចឱ្យសិស្សខ្ចីសម្ភារៈជួសជុលដើម្បីទៅ សិក្សានៅផ្ទះបាន ហើយនៅសប្តាហ៍ក្រោយក្នុងម៉ោងបំណិនជីវិតពួកគេត្រូវផ្តល់មកវិញ ប៉ុន្តែគ្រូត្រូវគ្រប់គ្រងការខ្ចីនេះឱ្យបានល្អ ជៀសវាងការបាត់បង់។

រូបភាពដុំមុខ សម្រាប់សិស្សដាក់ស្លាកឈ្មោះ។



សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជាគំរូ និងការអនុវត្តដោយសិស្សដទៃទៀត។

ការដោះចេញ: ____________________________________________

____________________________________________

____________________________________________។

ការជួសជុល: ____________________________________________

____________________________________________

____________________________________________។

ការដាក់ចូល: ____________________________________________

____________________________________________

____________________________________________

____________________________________________។

# មេរៀនទី ៥: របៀបជួសជុលដុំក្រោយ

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

កង់ សោមាត់លេខ១៤-១៥ ១៦-១៧ ដង្កាប់មាត់ក្រពើ ដង្កាប់ស្វ័យប្រវត្តិ កន្សែងឬសាច់កំណាត់ ដំឡាប់ ចានសន្ទះចាន រ៉ែងកាសស្តើង ខ្មៅកាស់ស្តើង-ក្រាស់ គ្រាប់ ខ្លាញ់គោ ភ្លៅក្រោយ១សម្រាប់។ *ចំណាំ៖ សម្ភារៈ និងឧបករណ៍ត្រូវមាន៥ សម្រាប់ (គ្រូ ១ សម្រាប់ សិស្ស៤ក្រុម ៤សម្រាប់)។*

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- បង្ហាញពីរបៀបជួសជុលដុំក្រោយ តាមលំដាប់លំដោយបានត្រឹមត្រូវ
- អនុវត្តបំណិនប្រសប់ពីរបៀបជួសជុលដុំក្រោយ បានត្រឹមត្រូវ
- ប្រាប់ពីរបៀបប្រើប្រាស់ និងមានទម្លាប់ថេរៈថែទាំឱ្យបានល្អ យូរអង្វែង
- អនុវត្តបំណិននេះផ្សារភ្ជាបនឹងជីវភាពរស់នៅជាក់ស្តែង ឬធ្វើជាអាជីព។

**សេចក្តីផ្តើម** 🕑 ១០ នាទី

👄 ដើម្បីពិនិត្យកិច្ចការដែលបានដាក់ឱ្យសិស្សធ្វើកាលពីសប្តាហ៍មុន គ្រូសួរសំណួរជាក្រុមធំ៖ នៅពេលកង់របស់ប្អូនៗខូចដុំក្រោយ ហើយទៅឱ្យជាងកង់ជួសជុល តើប្អូនៗសង្កេតឃើញជាងកង់មានសកម្មភាពដូចម្តេចខ្លះ? តើជាងបានប្រើប្រាស់សម្ភារៈជួសជុលអ្វីខ្លះ? ចូរប្អូនរៀបរាប់សកម្មភាពតាមលំដាប់លំដោយ។

✏ សរសេរចម្លើយនៅលើក្តារខៀន ដោយបែងចែក ចម្លើយដែលជាសកម្មភាពជួសជុល និង សម្ភារៈប្រើប្រាស់ ដូចខាងក្រោម៖

| សកម្មភាពជួសជុលដុំកង់ក្រោយ | សម្ភារៈប្រើប្រាស់ |
|---|---|
| | |

## សកម្មភាពសំខាន់។

🕑 ៦៥ នាទី

យើងនឹងធ្វើការជា៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ គ្រូនឹងអនុវត្តបង្ហាញពីការជួសជុលដុំក្រោយ ទន្ទឹមនឹងនោះ សមាជិកម្នាក់តំណាងឱ្យក្រុមនីមួយៗត្រូវអនុវត្តតាម ហើយសមាជិកក្នុង ក្រុមត្រូវសង្កេត កត់ត្រា លើគ្រប់សកម្មភាពលើឯកសារចែកឱ្យ។

គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេមកអនុវត្តក្នុងការសិក្សានេះ ផងដែរ ។

តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

គ្រូចាប់ផ្តើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តំណាងក្រុមនីមួយៗអនុវត្តតាម អ្នកដែលនៅសល់ ក្នុងក្រុមធ្វើការសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយ។ សកម្មភាពទាំងឡាយ ត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖

- ដោះចេញ៖ ដាក់កង់បញ្ឈរ ដោះខ្ចៅទប់កង់ក្រោយ ចេញ យកចន្ទល់ចេញពីភ្លៅ ដោះកង់ ចេញពីជំពាស់ ក្រោយ និងដោះច្រវាក់ចេញពីលីប។



- ជួសជុល៖ ដោះខ្ចៅទប់ ដោះខ្ចៅកាស់ ដោះរ៉ង កាស់ស្តើង និងខ្ចៅដំឡាប់ចេញផ្នែកម្ខាង ខាង ជន្ទល់ចេញទាំងអស់ ឬយកខ្ចៅចេញទាំងអស់ពីភ្លៅ បើសិនដំឡាប់ខូច។ យកគ្រាប់ ចេញពីក្នុងចាន ទាំងសងខាង។ ជូតខ្ចៅរ៉ង ខ្ចៅកាស់ ដំឡាប់ គ្រាប់ ភ្លៅ ដែលបាន ដោះចេញទាំងអស់ និងចានក្នុងដុំឱ្យបានស្អាត រកមើលកន្លែងខូច បើខូចត្រង់ណាមួយ ត្រូវផ្លាស់ចេញ ចំពោះគ្រាប់បើមានខូចត្រូវផ្លាស់ចេញទាំងអស់។ ត្រូវមួលខ្ចៅ ដំឡាប់ រ៉ងស្តើង និងខ្ចៅកាស់ ឱ្យងាប់នៅខាងលីប កុំឱ្យមួលចូលក្នុងបាន។ យកខ្លាញ់គោ មកលាបក្នុងចាន បន្តិច រៀបគ្រាប់ក្នុងចាន ឱ្យពេញទាំងសងខាង រួចយកខ្លាញ់គោ មកបៀកឱ្យពេញ ក្នុងចាន។ ស៊កភ្លៅចូលពី ខាងលីបទៅក្នុងដុំវិញ មួលខ្ចៅដំឡាប់ចូលឱ្យតឹងតែអាចវិលភ្លៅបាន ដាក់រ៉ង ស្តើងចូល និងមួលខ្ចៅកាស់ ចូលឱ្យតឹង។



● ដាក់ចូល៖ យកច្រវាក់មក ពាក់នឹងលីប ដាក់កង់ចូលក្នុងជំពាស់ក្រោយវិញ ដាក់ជន្ទល់ចូលក្នុងភ្លៅ មួលខ្ចៅទប់ ចូលបន្តិចកែសម្រួល ខ្ទងកង់ឱ្យចំកណ្ដាល និង កែសម្រួលច្រវាក់ឱ្យតឹងល្មម រួចរឹតខ្ចៅទប់ ទាំងសងខាងឱ្យបាន តឹងជាការ ស្រេច។

បើសិនជាមានពេលវេលា គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកផ្សេងៗក្នុងក្រុមជាអ្នកអនុវត្ត។



**បញ្ចប់មេរៀន** ១៥ នាទី

យកកង់ដែលជួសជុលដុំក្រោយរួច មកដាក់តាំងបង្ហាញ។

ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយឡើងវិញ។

ពេលត្រឡប់ទៅផ្ទះវិញ ប្អូនត្រូវហ្វឹកហាត់ពីរបៀបជួសជុលដុំក្រោយឱ្យបានស្ទាត់ជំនាញ។ នៅសប្ដាហ៍ក្រោយយើងសិក្សាពីរបៀបជួសជុលដំឡាប់ក សូមប្អូនៗទៅសិក្សាស្រាវជ្រាវ នៅផ្ទះជាងជួសជុលកង់ កត់ត្រាពីសកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្ដីណែនាំគ្រូ

● នៅក្នុងផ្នែក "បញ្ចប់មេរៀន" គ្រូឱ្យសិស្សរៀបរាប់សកម្មភាពសិក្សាឡើងវិញ បន្តរៀងគ្នា ពីក្រុមមួយទៅក្រុមមួយ មិនមែនឱ្យក្រុមនីមួយៗរៀបរាប់គ្រប់សកម្មភាព តាមលំដាប់ លំដោយនោះទេ។

● នៅចុងបញ្ចប់មេរៀននីមួយៗ គ្រូត្រូវតែឱ្យសិស្សទៅសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះ។ សិស្សមួយចំនួនអាចធ្វើការសិក្សាបានតាមរយៈការសាកសួរឪពុកម្ដាយ បងប្អូន ឬជាមួយជាងនៅក្នុងសហគមន៍នោះ។ ក្នុងករណីចាំបាច់ គ្រូអាចឱ្យសិស្សខ្ចីសម្ភារៈជួសជុលដើម្បីទៅ សិក្សានៅផ្ទះបាន ហើយនៅសប្ដាហ៍ក្រោយក្នុងម៉ោងបំណិនជីវិតពួកគេត្រូវផ្ដល់មកវិញ ប៉ុន្តែគ្រូត្រូវគ្រប់គ្រងការខ្ចីនេះឱ្យបានល្អ ជៀសវាងការបាត់បង់។

រូបភាពដុំក្រោយ សម្រាប់សិស្សដាក់ស្លាកឈ្មោះ។



សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជាគំរូ និងការអនុវត្តដោយ-សិស្សដទៃទៀត។

ការដោះចេញ: ..............................................................................................................

..............................................................................................................

..............................................................................................................។

ការផ្គុំសណ្តុំ: ..............................................................................................................

..............................................................................................................

..............................................................................................................។

ការដាក់ចូល: ..............................................................................................................

..............................................................................................................

..............................................................................................................។

# មេរៀនទី ៦: របៀបជួសជុលដំឡាប់ក

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

កង់ សោមាត់លេខ១២-១៣ ញញួរ ដង្កាប់ស្វ័យប្រវត្តិ កន្សែងឬកំណាត់ ខ្លាញ់គោ កសេះ ខ្ចៅកូនជញ្ជីង ដំឡាប់ចាន គ្រាប់ រ៉ងធ្មេញរណា ខ្ចៅកាស់ ដំឡាប់ក១សម្រាប់

*ចំណាំ៖ សម្ភារៈ និង ឧបករណ៍ត្រូវមាន៥ សម្រាប់ (គ្រូ ១ សម្រាប់, សិស្ស៤ក្រុម ៤សម្រាប់)។*

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- បង្ហាញពីរបៀបជួសជុលដំឡាប់ក តាមលំដាប់លំដោយបានត្រឹមត្រូវ
- អនុវត្តបំណិនប្រសប់ពីរបៀបជួសជុលដំឡាប់ក បានត្រឹមត្រូវ
- ប្រាប់ពីរបៀបប្រើប្រាស់ និងមានទម្លាប់ថេះថៃទាំឱ្យបានល្អ យូរអង្វែង
- អនុវត្តបំណិននេះផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្តែង ឬធ្វើជាអាជីព។

## សេចក្តីផ្តើម

🕑 ១០ នាទី

👄 នៅពេលប្អូនៗខូចកង់ត្រង់ផ្នែកដំឡាប់ក ហើយយកទៅឱ្យជាងកង់ជួសជុល តើប្អូនៗសង្កេតឃើញថា ជាងកង់មានសកម្មភាពដូចម្តេចខ្លះ? តើផ្នែកដំឡាប់កមានអ្វីខ្លះ? ហើយប្រើសម្ភារៈអ្វីខ្លះ? សូមប្អូនៗ ប្រើក្រដាសរ៉ាមអា៤ រួចគូររូបផ្នែកណាមួយ សកម្មភាព ឬសម្ភារៈជួសជុល ដែលទាក់ទងនឹង ផ្នែកដំឡាប់កនេះរយៈពេល៥នាទី។ ម្នាក់ៗគូរតែមួយចំណុចបានហើយ។

✋ គ្រូចែកក្រដាសរ៉ាមអា.៤ ហើយឱ្យសិស្សចាប់ផ្តើមគូររូប។

👄 បន្ទាប់ពីរយៈពេល៥នាទីគ្រូឱ្យពួកគេម្នាក់បង្ហាញ និងពន្យល់ទៅកាន់អ្នកដែលនៅក្បែរជាដៃគូ។ បន្ទាប់មកឱ្យសិស្សស្ម័គ្រចិត្តឡើងបង្ហាញរូបភាពរបស់ខ្លួន ដោយប្រាប់ពីឈ្មោះផ្នែកនៃដំឡាប់ក ឬសម្ភារៈជួសជុល។ សិស្សដែលស្ម័គ្រចិត្តឡើងមកបង្ហាញគួរតែប្រាប់ពីអ្វី ដែលមានភាពខុសគ្នាពីម្នាក់ទៅម្នាក់។

## សកម្មភាពសំខាន់។ ⏲ ៦៥ នាទី

យើងនឹងធ្វើការជា៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ គ្រូនឹងអនុវត្តបង្ហាញពីការជួសជុលជុំមុខ ទន្ទឹមនឹងនោះ សមាជិកម្នាក់តំណាងឱ្យក្រុមនីមួយៗត្រូវអនុវត្តតាម ហើយសមាជិកក្នុង ក្រុមត្រូវសង្កេត កត់ត្រា គ្រប់សកម្មភាពលើឯកសារចែកឱ្យ។

គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេមកអនុវត្តក្នុងការសិក្សានេះ ផងដែរ ។

តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

គ្រូចាប់ផ្ដើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តំណាងក្រុមនីមួយៗអនុវត្តតាម អ្នកដែលនៅសល់ ក្នុងក្រុមធ្វើការសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយ។ សកម្មភាពទាំងឡាយ ត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖

● ដោះចេញ៖ ដោះខ្ចៅកូនជញ្ជីងឱ្យលូតផុតពីកសេះប្រវែង ១ហ៊ុន យកញញួរមកដំក្បាល ខ្ចៅទម្លាក់ចុះ ដោះយកកសេះចេញ។ ដាក់កង់ផ្អេក ដោះខ្ចៅរ៉ងចេញ ដោះរ៉ងកាស ធ្មេញរណា មួលខ្ចៅចានចេញ ដក ជំពាស់ចេញពីកទូក ត្រូវយកកន្សែង ឬកំណាត់ មកក្រាលពីក្រោមកុំ ឱ្យគ្រាប់ជ្រុះចេញពីចានខ្ទាតឆ្ងាយ ឬបាត់។



● ជួសជុល៖ ជូតចាន ដំឡាប់ គ្រាប់ រ៉ង ខ្ចៅ កាស់ឱ្យស្អាត រកមើលកន្លែងខូច បើខូចត្រង់ ណាត្រូវផ្លាស់ចេញ។ យកខ្លាញ់គោមកលាបក្នុងចានបន្តិច រៀបគ្រាប់ឱ្យពេញ ក្នុងចាន ទាំងខាងលើនិងខាងក្រោម ដាក់ជំពាស់ចូលក្នុង កទូកវិញ មួលខ្ចៅដំឡាប់ចូលឱ្យតឹងតែអាចវិលជំពាស់ បាន ដាក់រ៉ងធ្មេញរណា មួលខ្ចៅរ៉ង កាស់ឱ្យតឹង។



● ដាក់ចូល៖ ដាក់កង់បញ្ឈរ ដាក់កសេះចូលក្នុងក ជំពាស់វិញ រិតខ្ចៅកូនជញ្ជីងឱ្យតឹង ដោយយេបង្វិលដៃចង្កូតឱ្យត្រង់ស្របនឹងកង់ខាងមុខជាការស្រេច។



🖐 បើសិនជាមានពេលវេលានៅសល់ គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកផ្សេងៗក្នុងក្រុមជាអ្នកអនុវត្ត។

## បញ្ចប់មេរៀន

🕑 ១៥ នាទី

🖐 យកកង់ដែលជួសជុលដំឡាប់ករួច មកដាក់តាំងបង្ហាញ។

👄 ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយឡើងវិញ។

👄 ពេលត្រឡប់ទៅផ្ទះវិញ ប្អូនត្រូវហ្វឹកហាត់ពីរបៀបជួសជុលខំឡាប់កឱ្យបានស្ទាត់ជំនាញ។ នៅសប្តាហ៍ក្រោយយើងសិក្សាពីរបៀបដោះកាំ និងដំឡើងកាំ សូមប្អូនៗទៅសិក្សាស្រាវជ្រាវ នៅផ្ទះជាងជួសជុលកង់ កត់ត្រាពីសកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្តីណែនាំគ្រូ

● នៅក្នុងផ្នែក "បញ្ចប់មេរៀន" គ្រូឱ្យសិស្សរៀបរាប់សកម្មភាពសិក្សាឡើងវិញ បន្តរៀងគ្នា ពីក្រុមមួយទៅក្រុមមួយ មិនមែនឱ្យក្រុមនីមួយៗរៀបរាប់គ្រប់សកម្មភាព តាមលំដាប់ លំដោយនោះទេ។

● នៅចុងបញ្ចប់មេរៀននីមួយៗ គ្រូត្រូវតែឱ្យសិស្សទៅសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះ។ សិស្ស មួយ ចំនួនអាចធ្វើការសិក្សាបានតាមរយៈការសាកសួរឪពុកម្តាយ បងប្អូន ឬជាមួយជាងនៅក្នុងសហគមន៍នោះ។ ក្នុងករណីចាំបាច់ គ្រូអាចឱ្យសិស្សខ្ចីសម្ភារៈជួសជុលដើម្បីទៅ សិក្សានៅផ្ទះបាន ហើយនៅសប្តាហ៍ក្រោយក្នុងម៉ោងបំណិនជីវិតពួកគេត្រូវផ្តល់មកវិញប៉ុន្តែ គ្រូត្រូវគ្រប់គ្រងការខ្ចីនេះឱ្យបានល្អ ជៀសវាងការបាត់បង់។

រូបភាពផ្នែកផ្សេងៗនៃដុំឡាប់ក សម្រាប់ឱ្យសិស្សដាក់ស្លាកឈ្មោះ ។



សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជាគំរូ និងការអនុវត្តដោយ-សិស្សដទៃទៀត ។

ការដោះចេញ: ....................................................................................................................

....................................................................................................................................

.................................................................................................................................... ។

ការជួសជុល: ....................................................................................................................

....................................................................................................................................

.................................................................................................................................... ។

ការដាក់ចូល: ....................................................................................................................

....................................................................................................................................

.................................................................................................................................... ។

# មេរៀនទី ៧: របៀបដោះកាំ និងដំឡើងកាំ

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើល ព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- កង់ ជើងរិតកាំ សោរិតកាំ សោមាត់លេខ ១៤-១៥ ឬ១៦-១៧ ខ្នងកង់មុខ-ក្រោយ ដុំកង់មុខ-ក្រោយ កាំមុខ-ក្រោយ។ ចំណាំៈ សម្ភារៈ និងឧបរកណ៍ត្រូវមាន៥ សម្រាប់ (គ្រូ ១ សម្រាប់, សិស្ស៤ក្រុម ៤សម្រាប់)។
- រូបគំនូរ និងការពិពណ៌នាសម្រាប់សិស្សម្នាក់អាន

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- បង្ហាញដឹងពីរបៀបដោះកាំ និងដំឡើងកាំ បានត្រឹមត្រូវ
- រៀបរាប់ពីបំណិនប្រសប់ពីរបៀបដោះកាំ និងដំឡើងកាំ បានត្រឹមត្រូវ
- អនុវត្តបំណិននេះផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្តែង ឬធ្វើជាអាជីព

## សេចក្តីផ្តើម 🕑 ១០ នាទី

✋ ជ្រើសរើសសិស្សម្នាក់ ហើយនិយាយណែនាំពីអ្វីដែលត្រូវធ្វើកុំឱ្យសិស្សផ្សេងទៀតបានឮ និង ផ្តល់ក្រដាសរ៉ាម អា.៤ ឱ្យសិស្សទាំងអស់ក្នុងថ្នាក់។

👄 ដើម្បីចាប់ផ្តើមមេរៀននៅថ្ងៃនេះ គ្រូផ្តល់ឱ្យសិស្សម្នាក់នូវគំនូរងាយមួយដែលមានស្ថានភាពទាក់ទងនឹង ប្រធានបទ *(សូមមើលរូបគំនូរ និងការពណ៌នា)*។ ឱ្យសិស្សម្នាក់នេះប្រាប់ពីទិដ្ឋភាព និងទីតាំងគំនូរនោះទៅសិស្ស ដទៃទៀត។ សិស្សផ្សេងៗទៀតត្រូវគូររូបនោះទៅតាមការណែនាំ របស់សិស្សដែលកំពុងកាន់គំនូរពិតប្រាកដនេះ។

✋ បន្ទាប់ពីបញ្ចប់ កិច្ចការនេះ ត្រូវរកមើល ថាតើរូបភាពណាដែលមានភាពស្រដៀងបំផុត នឹងរូបភាព ជាក់ស្តែង។ លំហាត់នេះផ្តោតជាសំខាន់ទៅលើទីតាំង និង ទំហំនៃវត្ថុជាជាងផ្នែកល្អិតល្អន់ផ្សេងៗទៀត។

ការពណ៌នា៖ សូមគូសរង្វង់មួយទំហំធំល្មម។ នៅចំ កណ្តាលរង្វង់នោះត្រូវគូសរង្វង់តូចមួយទៀត។ រួចមកគូសបន្ទាត់គភ្ជាប់ពីរង្វង់តូចទៅកាន់រង្វង់ធំបន្តរៀងគ្នា។ បន្ទាត់នីមួយៗមាន ចន្លោះកន្លះ ឬ១សង់ទីម៉ែត្រ រហូតដល់ពេញរង្វង់។ បន្ទាប់មកគូរគំនូរមួយផ្សេងទៀត មានរាងដូចចំពាមកៅស៊ូ ប៉ុន្តែមានទំហំធំល្មមអាចទ្រង្វង់ដែលទើបតែគូសរួចហើយ។

👄 បញ្ជាក់បន្ថែមដល់សិស្សពីសម្ភារៈដែលត្រូវការសម្រាប់ដោះកាំ និងរឹតកាំ។

## សកម្មភាពសំខាន់។

⏲ ៦៥ នាទី

យើងនឹងធ្វើការជា៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ គ្រូនឹងអនុវត្តបង្ហាញពីការជួសជុលដុំមុខ ទន្ទឹមនឹងនោះ សមាជិកម្នាក់នៅក្នុងក្រុមនីមួយៗត្រូវអនុវត្តតាម ហើយសមាជិកក្នុង ក្រុមត្រូវសង្កេត កត់ត្រា លើគ្រប់សកម្មភាពលើឯកសារចែកឱ្យ។

គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេមកអនុវត្តក្នុងការសិក្សានេះ ផងដែរ ។

តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

គ្រូចាប់ផ្ដើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តំណាងឱ្យក្រុមនីមួយៗអនុវត្តតាម អ្នកដែលនៅសល់ ក្នុងក្រុមធ្វើការសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយ។ សកម្មភាពទាំងឡាយ ត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖



● ដោះចេញ៖ យកកង់មុខមកដាក់ក្នុងជើងរឹតកាំ មួលខ្ចៅទប់ទាំងសងខាងឱ្យតឹងបន្តិច។ យកសោមកដោះ ដោយមួលខ្ចៅក្បាលកាំចេញមួយជុំក្បាល កាំមួយម្ដងៗគ្រប់ក្បាលកាំទាំងអស់។ បន្តបន្ទូរ ឬមួលខ្ចៅ ក្បាលកាំចេញ ២ជុំ ក្បាលកាំមួយម្ដងៗគ្រប់ក្បាលកាំទាំងអស់ ឱ្យបានស្មើៗគ្នា រហូតដល់ក្បាលកាំទាំងអស់ដោះចេញពីខ្នង។ ដោះដុំ កង់ចេញពីជើងរឹតកាំ និងយកកាំចេញពីដុំ។

● ដាក់ចូល៖ យកកាំមកស៊កបញ្ចូលក្នុងប្រហោងក្បាលកាំ ជាប់នឹងដុំ ដោយរំលងគ្នាមួយៗ ឆ្លាស់គ្នាទាំង សងខាង។ យកកាំឆ្លាស់គ្នារំលង៦ឬ៨ មកភ្ជាប់នឹងខ្នងរំលងគ្នាមួយៗ។ ពេលភ្ជាប់នៅម្ខាងអស់ ហើយត្រូវបន្តធ្វើនៅម្ខាងទៀត ទាល់តែអស់ដោយមួល ខ្ចៅក្បាល កាំចូលឱ្យបានប្រវែងស្មើៗគ្នា ក្នុង ខ្ចៅ ក្បាលកាំ។



បើសិនជាមានពេលវេលានៅសល់ គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកផ្សេងៗក្នុងក្រុមជាអ្នកអនុវត្ត។

**បញ្ចប់មេរៀន** ១៥ នាទី

យកខ្នងកង់ដែលដំឡើងរួច មកដាក់តាំងបង្ហាញ។

ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយឡើងវិញ។

ពេលត្រឡប់ទៅផ្ទះវិញ ប្អូនត្រូវហ្វឹកហាត់ពីរបៀបដោះកាំ និងដំឡើងកាំឱ្យបានស្ទាត់ជំនាញ។ នៅសប្តាហ៍ក្រោយ យើងសិក្សាពីរបៀបរិតក្បាលកាំ សូមប្អូនៗទៅសិក្សាស្រាវជ្រាវ នៅផ្ទះជាងជួសជុលកង់ កត់ត្រាពីសកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្តីណែនាំគ្រូ

- នៅពេលសិស្សរៀបកាំចប់ គ្រូត្រូវរក្សាទុកសម្រាប់សិស្សប្រើប្រាស់នៅក្នុងមេរៀនសប្តាហ៍ ក្រោយ អំពីការរិតក្បាលកាំ។

រូបភាពអំពីខ្នងកង់មុខ ដែលមានកាំ ក្បាលកាំ ជំពាក់សម្រាប់ឱ្យសិស្សដាក់ស្លាក ឈ្មោះ ។



សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជា គំរូ និងការ អនុវត្តដោយសិស្ស-ដទៃទៀត ។

ការដោះចេញ: ..................................................................................................

..................................................................................................................

..................................................................................................................។

ការជួសជុល: ..................................................................................................

..................................................................................................................

..................................................................................................................។

ការដាក់ចូល: ..................................................................................................

..................................................................................................................

..................................................................................................................។

# មេរៀនទី ៨: របៀបរឹតក្បាលកាំ

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរនៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើល ព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន ( តុ កៅអី ក្តារខៀន... )

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

ខ្នងកង់មុខ-ក្រោយ ដុំកង់មុខ-ក្រោយ កាំមុខ-ក្រោយ សោមាត់លេខ ១៤-១៥ និង ១៦-១៧ សោ រឹតកាំ ជើងរឹតកាំ។ ចំណាំៈ សម្ភារៈ និង ឧបរកណ៍ត្រូវមាន៥សម្រាប់ ( គ្រូ ១ សម្រាប់សិស្ស៤ក្រុម ៤សម្រាប់ )។

☼ លទ្ធផលរំពឹងទុក

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ប្រាប់ពីរបៀបរិតក្បាលកាំ តាមលំដាប់លំដោយបានត្រឹមត្រូវ
- អនុវត្តបំណិនរិតក្បាលកាំ បានត្រឹមត្រូវ
- បង្ហាញពីរបៀបប្រើប្រាស់ និងថេះថែទាំឱ្យបានល្អយូរអង្វែង
- អនុវត្តបំណិននេះផ្សារភ្ជាបនឹងជីវភាពរស់នៅជាក់ស្តែង ឬធ្វើជាអាជីព។

## សេចក្តីផ្តើម

🕑 ១៥ នាទី

👄 នៅពេលប្អូនៗខូចកង់ត្រង់ផ្នែកកាំកង់ ឬខ្នងកង់ ហើយយកទៅឱ្យជាងកង់ជួសជុល ឬប្តូរកាំ-ខ្នង តើប្អូនៗសង្កេតឃើញជាងកង់មានសកម្មភាពដូចម្តេចខ្លះ ? គ្រូឱ្យសិស្សស្ម័គ្រចិត្តឡើងផ្តល់យោបល់ ទៅតាមការយល់ដឹងរបស់ពួកគេ។

✋ ក្នុងពេលដែលសិស្សឆ្លើយគ្រូសរសេរចម្លើយនៅលើក្តារខៀន។ គ្រូធ្វើការបូកសរុប បំពេញ បន្ថែម លើចម្លើយដែលបានផ្តល់ រួចហើយបង្ហាញ និងពន្យល់ប្រាប់ពីផ្នែកកាំកង់ ឬខ្នងកង់ ជាក់ស្តែង ដោយយកខ្នងកង់ដែលបានរៀបកាំកាលពីសប្តាហ៍មុន។

👄 នៅពេលអនុវត្តជាក់ស្តែង យើងនឹងទៅសិក្សានៅក្រៅថ្នាក់រៀន។

## សកម្មភាពសំខាន់។

🕑 **65** នាទី

👄 យើងនឹងធ្វើការជា៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ គ្រូនឹងអនុវត្តបង្ហាញពីការជួសជុលដុំមុខ ទន្ទឹមនឹងនោះ សមាជិកម្នាក់តំណាងឱ្យក្រុមនីមួយៗត្រូវអនុវត្តតាម ហើយសមាជិកក្នុង ក្រុមត្រូវសង្កេត កត់ត្រា លើគ្រប់សកម្មភាពលើឯកសារចែកឱ្យ។

☝ គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេមកអនុវត្តក្នុងការសិក្សានេះ ផងដែរ ។

◈ តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

☝ គ្រូចាប់ផ្តើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តំណាងឱ្យក្រុមនីមួយៗអនុវត្តតាម អ្នកដែលនៅសល់ ក្នុងក្រុមធ្វើការសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយ។ សកម្មភាពទាំងឡាយ ត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖

● យកខ្នងកង់ដែលបានដំឡើងរួច មកដាក់ក្នុងជើងរិតកាំ រួចមួល ខ្មៅទប់ឱ្យតឹងល្មម។ រឹតខ្មៅក្បាលកាំចូលបន្តិចម្តងៗឱ្យបានមួយជុំ រួចបន្តរិតឱ្យបានស្មើៗគ្នារហូតដល់កាំកង់បានតឹងល្មម គឺមិនធូរពេក មិនតឹងពេក។



● តម្រង់រង្វង់ខ្នង៖ បង្វិលខ្នងកង់តិចៗឱ្យបានមួយជុំ ពិនិត្យមើលត្រង់ណាប៉ះ និងឃ្លាតពីកម្រិតខ្នាតរង្វង់។ បើត្រង់ណាប៉ះ នឹងកម្រិតខ្នាត ត្រូវមួល រឹត បន្ថែម តែបើត្រង់ណាឃ្លាតពីកម្រិតខ្នាតរង្វង់ ត្រូវមួលបន្ធូរ ធ្វើរបៀបនេះសាចុះសាឡើង រហូត ដល់ខ្នងកង់រត់ត្រង់ ស្មើ ដោយមិនរលក ឬពង ក្រពើ។



● តម្រង់ចំហៀងខ្នង៖ បង្វិលខ្នងកង់តិចៗឱ្យបានជុំពិនិត្យមើលត្រង់ណាប៉ះ និងឃ្លាតពីកម្រិតខ្នាត ចំហៀងខ្នង។បើត្រង់ណាប៉ះនឹងកម្រិតខ្នាតដែល នៅខាងស្តាំដៃត្រូវមួលខ្មៅ ក្បាលកាំនៅផ្នែកខាង ស្តាំបន្ធូរបន្តិច រួចមួលខ្មៅក្បាលកាំផ្នែកខាង ឆ្វេង បន្ថែមបន្តិច ធ្វើរបៀបនេះសាចុះសាឡើង រហូតខ្នងកង់ផ្នែកចំហៀងរត់ ត្រង់ស្មើ ដោយមិន រមួល។

● ក្នុងការរឹតក្បាលកាំតម្រង់រង្វង់ខ្នង និងចំហៀងខ្នង ត្រូវការសម្រួលគ្នាទាំងព្រម។

☝ បើសិនជាមានពេលវេលានៅសល់ គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកផ្សេងៗក្នុងក្រុមជាអ្នកអនុវត្ត។

**បញ្ចប់មេរៀន** ១៥ នាទី

យកកង់ដែលជួសជុលរួច មកដាក់តាំងបង្ហាញ។

ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយឡើងវិញ។

ពេលត្រឡប់ទៅផ្ទះវិញ ប្អូនត្រូវហ្វឹកហាត់ពីរបៀបរិតក្បាលកាំ ឱ្យបានស្ទាត់ជំនាញ។ នៅសប្តាហ៍ក្រោយយើងសិក្សាពីរបៀបជួសជុល ហ្វ្រាំងមុខ - ហ្វ្រាំងក្រោយ សូមប្អូនៗទៅសិក្សាស្រាវជ្រាវ នៅផ្ទះជាងជួសជុលកង់ កត់ត្រាពី សកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

## សេចក្តីណែនាំគ្រូ

- ក្នុងការសិក្សាលើផ្នែករិតកាំ ដែលក្នុងនោះសិស្សនឹងសិក្សាលើការតម្រង់ខ្នងកង់ និង ចំហៀងខ្នង កង់នេះ យើងមិនរំពឹងថាសិស្សនឹងមានជំនាញបានច្បាស់លាស់នោះទេ ប៉ុន្តែ សិស្សគ្រាន់តែដឹង អំពីរបៀបក្នុងការជួសជុលមួយចំនួនប៉ុណ្ណោះ។

បញ្ចូលរូបភាពខ្លួងកង់ដែលមានខ្នាតវាស់រង្វង់ខ្លួង និង ចំហៀងខ្លួង ដើម្បីឱ្យសិស្សដាក់ស្លាក ឈ្មោះ។



សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជា គំរូ និងការអនុវត្តដោយសិស្ស-ដទៃទៀត។

ការដោះចេញ: ..............................................................................................................

..............................................................................................................................

..............................................................................................................................។

ការជួសជុល: ..............................................................................................................

..............................................................................................................................

..............................................................................................................................។

ការដាក់ចូល: ..............................................................................................................

..............................................................................................................................

..............................................................................................................................។

# មេរៀនទី ៩: របៀបជួសជុលហ្វ្រាំងមុខ - ក្រោយ

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

ដៃហ្វ្រាំងមុខ-ក្រោយ ខ្សែហ្វ្រាំងមុខ-ក្រោយ ស្រោមហ្វ្រាំងមុខក្រោយ ជ័រជុំហ្វ្រាំង ហ្វ្រាំងថ្មីមួយកំប្លេ ដង្កាប់មាត់ក្រពើ ទួណឺវីស សោមាត់លេខ ៨-៩ និង ១០-១១ និង ១២-១៣ ខ្លាញ់គោ។

*ចំណាំ៖ សម្ភារៈនិង ឧបករណ៍ត្រូវមាន៥ សម្រាប់ (គ្រូ ១ សម្រាប់ សិស្ស៤ក្រុម ៤សម្រាប់)។*

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- ប្រាប់ពីរបៀបជួសជុល ហ្វ្រាំងមុខ-ក្រោយបានត្រឹមត្រូវ
- អនុវត្តបំណិនជួសជុល ហ្វ្រាំងមុខ-ក្រោយបានត្រឹមត្រូវ
- បង្ហាញពីរបៀបប្រើប្រាស់ និងៈថែទាំឱ្យបានល្អយូរអង្វែង
- អនុវត្តបំណិននេះផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្ដែង ឬធ្វើជាអាជីព។

## សេចក្ដីផ្ដើម

🕑 ១០ នាទី

ដើម្បីត្រួតពិនិត្យកិច្ចការដែលបានដាក់ឱ្យសិស្សធ្វើកាលពីសប្ដាហ៍មុន គ្រូសួរសំណួរជាក្រុមធំ៖ នៅពេលកង់របស់ប្អូនៗខូច ហ្វ្រាំងមុខ-ក្រោយ ហើយយកទៅឱ្យជាងកង់ជួសជុល តើប្អូនៗសង្កេតឃើញជាងកង់មានសកម្មភាពដូចម្ដេចខ្លះ? តើជាងបាន ប្រើប្រាស់សម្ភារៈជួសជុលអ្វីខ្លះ? ចូរប្អូនរៀប រាប់សកម្មភាពតាមលំដាប់លំដោយ។

✎ សរសេរចម្លើយនៅលើក្ដារខៀន ដោយបែងចែក ចម្លើយដែលជាសកម្មភាពជួសជុល និង សម្ភារៈប្រើប្រាស់ដូចខាងក្រោម៖

| សកម្មភាពជួសជុលហ្វ្រាំង មុខ-ក្រោយ | សម្ភារៈប្រើប្រាស់ |
|---|---|
| | |

## សកម្មភាពសំខាន់។

🕑 ៦៥ នាទី

យើងនឹងធ្វើការជា៤ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ គ្រូនឹងអនុវត្តបង្ហាញពីការជួសជុលជុំមុខ ទន្ទឹមនឹងនោះ សមាជិកម្នាក់តំណាងឱ្យក្រុមនីមួយៗត្រូវអនុវត្តតាម ហើយសមាជិកក្នុង ក្រុមត្រូវសង្កេត កត់ត្រា លើគ្រប់សកម្មភាពលើឯកសារចែកឱ្យ។

គ្រូយកកង់មួយគ្រឿងមក ហើយឱ្យក្រុមនីមួយៗស្ម័គ្រចិត្តយកកង់របស់ពួកគេមកអនុវត្តក្នុងការសិក្សានេះ ផងដែរ ។

តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

គ្រូចាប់ផ្ដើមធ្វើសកម្មភាពបង្ហាញ សិស្សម្នាក់តាមក្រុមនីមួយៗអនុវត្តតាម អ្នកដែលនៅសល់ ក្នុងក្រុមធ្វើការសង្កេត និងកត់ត្រាសកម្មភាពតាមលំដាប់លំដោយ។ សកម្មភាពទាំងឡាយ ត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖

- ដោះចេញ៖ ដោះខ្ចៅរឹតចុងខ្សែហ្វ្រាំងចេញពីតង្កៀប ទាញស្រោមហ្វ្រាំងចេញពីខ្សែ ដោះក្បាលខ្សែចេញពីដៃហ្វ្រាំង និងពិនិត្យមើលក្រចាប់ដៃ។ ដោះខ្ចៅតង្កៀប ហ្វ្រាំងចេញ ពីក្បាលជំពាស់។



- ជួសជុល៖ ពិនិត្យមើលរកកន្លែងខូច បើខូចត្រង់ណាត្រូវផ្លាស់ចេញ ដូចជាក្រចាប់ដៃ ដៃ ហ្វ្រាំង ស្រោម ខ្សែ តង្កៀប រ៉ឺសស័រ ដុំជ័រ។

- ដាក់ចូល៖ រៀបតង្កៀប ហ្វ្រាំងរួច ចាប់ភ្ជាប់នឹងក្បាលជំពាស់ និង ចាប់ដុំជ័រហ្វ្រាំង ឱ្យកៀកនឹងខ្នង កង់។ យកក្បាលខ្សែ ហ្វ្រាំង មកដាក់ ចូលក្នុងឡុតដៃហ្វ្រាំង លាបខ្លាញ់ គោ



នឹងខ្សែស៊កចូលក្នុងស្រោម រូតស្រោមសា ចុះសាឡើងឱ្យខ្លាញ់ គោបានចូលសព្វក្នុងស្រោម រួច ចាប់ចុងខ្សែនឹង តង្កៀប ឱ្យតឹង ដោយស៊ីរ៉េជុំជំរឱ្យនៅសល់ បន្តិច ឬឱ្យនៅកៀកនឹងខ្នងកង់ជាការស្រេច។ របៀបជួសជុលហ្វ្រាំង ក្រោយ ធ្វើដូច ការជួសជុលហ្វ្រាំងមុខ ដែលបានរៀបរាប់ខាង លើ។

បើសិនជាមានពេលវេលានៅសល់ គ្រូឱ្យសិស្សអនុវត្តសាឡើងវិញ ដោយឱ្យសមាជិកផ្សេងៗក្នុងក្រុមជាអ្នកអនុវត្ត។

**បញ្ចប់មេរៀន** ១៥ នាទី

យកកង់ដែលជួសជុលហ្វ្រាំងមុខ-ក្រោយរួច មកដាក់តាំងបង្ហាញ។

ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយឡើងវិញ។

ពេលត្រឡប់ទៅផ្ទះវិញ ប្អូនត្រូវហ្វឹកហាត់ពីរបៀបជួសជុលហ្វ្រាំងមុខ-ក្រោយឱ្យបានស្ទាត់ជំនាញ។ នៅសប្តាហ៍ក្រោយយើងសិក្សាពីរបៀបដំឡើងតួកង់ សូមប្អូនៗទៅសិក្សាស្រាវជ្រាវ នៅផ្ទះជាងជួសជុលកង់ កត់ត្រាពីសកម្មភាពតាមលំដាប់លំដោយឱ្យបានគ្រប់ៗគ្នា។

បញ្ចូលរូបភាពហ្វ្រាំងមុខ-ក្រោយ ដើម្បីឱ្យសិស្សដាក់ស្លាកឈ្មោះ



សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជាគំរូ និងការអនុវត្តដោយ-សិស្សដទៃទៀត។

ការដោះចេញ៖ ..........................................................................................................

..........................................................................................................................

..........................................................................................................................។

ការជួសជុល៖ ..........................................................................................................

..........................................................................................................................

..........................................................................................................................។

ការដាក់ចូល៖ ..........................................................................................................

..........................................................................................................................

..........................................................................................................................។

# មេរៀនទី ១០: របៀបដំឡើងតួកង់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ/អ្នកគ្រូត្រូវ

- អាន និងពិនិត្យមើលមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថា តើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរនៅលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

គ្រឿងបន្លាស់កង់១គ្រឿង។ ចំណាំ៖ សម្ភារៈ និង ឧបករណ៍ជួសជុល តាមផ្នែកនៃកង់សម្រាប់ក្រុម នីមួយៗត្រូវមានគ្រប់ក្រុម។

☼ វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់ សិស្សទាំងអស់អាច ៖

- ប្រាប់ពីរបៀបដំឡើងកង់ បានត្រឹមត្រូវ
- អនុវត្តបំណិនដំឡើងកង់ បានត្រឹមត្រូវ
- បង្ហាញពីរបៀបប្រើប្រាស់ និងថែទាំឱ្យបានល្អយូរអង្វែង
- អនុវត្តបំណិននេះផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្ដែង ឬធ្វើជាអាជីព

## សេចក្ដីផ្ដើម

🕑 ១០ នាទី

👄 នៅក្នុងសប្ដាហ៍នេះគឺជាការបញ្ចប់មេរៀនអំពីការជួសជុលកង់។ ក្នុងរយៈពេលកន្លងមកយើង បានសិក្សា ទៅលើផ្នែកផ្សេងៗនៃតួកង់ទាំងមូល ហើយនៅសប្ដាហ៍នេះយើងនឹងរៀនអំពីការ ដំឡើងតួកង់ទាំងមូលតែម្ដង។

❓ គ្រូសួររំឭកជាក្រុមធំ។ តើកន្លងមកយើងបានសិក្សាទៅលើផ្នែកអ្វីខ្លះនៃកង់? សិស្សឆ្លើយ។

👄 មុននឹងចាប់ផ្ដើមសកម្មភាពរៀនបន្តទៅទៀតអំពីការដំឡើងតួកង់ទាំងមូល។ គ្រូឱ្យសិស្សលេង ល្បែងមួយប្រភេទមានឈ្មោះថា ល្បែងបាល់ក្រដាស។ គ្រូឱ្យសិស្សគិតរកសំណួរទាក់ទងនឹង ផ្នែកផ្សេងៗនៃកង់កន្លងមក ហើយសរសេរសំណួរនោះនៅលើក្រដាសអា.៤។ សិស្សម្នាក់អាចសរសេរ ១ ឬ ២ ឬ៣ សំណួរ រួចហើយ សិស្សច្របាច់ក្រដាសទាំងនោះទៅជាបាល់មួយ។ នៅពេលយើងបានដឹងថា សិស្សសរសេរបានសំណួរមួយចំនួនហើយ ឱ្យសិស្សឈរជារង្វង់មូល។ សិស្សម្នាក់រើសយកបាល់របស់ខ្លួន បោះទៅឱ្យសិស្សផ្សេងៗទៀតក្នុងខណៈ ដែលគ្រូរាប់ពី១-១០។

ពេលរាប់ដល់១០ អ្នកដែលទទួលបានបាល់នោះ ត្រូវលាក្រដាសបាល់ ហើយឆ្លើយសំណួរ។ ពេលឆ្លើយចប់ ត្រូវបន្តអនុវត្តជាមួយបាល់របស់សិស្សផ្សេងៗទៀត។

## សកម្មភាពសំខាន់។

🕑 ៣៥ នាទី

ក្នុងការរៀនដំឡើងតួកង់ទាំងមូលនេះ គ្រូត្រូវដាក់សំបក ពោះវៀនកង់មុខ-ក្រោយ និងចាប់លីប ឱ្យហើយ ជាមុន។ យើងនឹងធ្វើការជា៣ក្រុម ក្នុងមួយក្រុមៗមានសមាជិក៥នាក់។ សិស្សនឹង អនុវត្តបង្ហាញពីការដំឡើងផ្នែកផ្សេងៗនៃកង់។ នៅពេលអនុវត្តត្រូវសហការគ្នា ដោយបែងចែក ផ្នែកនីមួយៗតាមក្រុម។

គ្រូពិនិត្យមើលថាតើផ្នែកផ្សេងៗនៃកង់ និងសម្ភារៈប្រើប្រាស់ត្រូវបានត្រៀមរួចរាល់ហើយឬនៅមុននឹងចាប់ផ្តើម។
តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

អនុញ្ញាតឱ្យសិស្សតាមក្រុមនីមួយៗចាប់ផ្តើមដំឡើង ហើយគ្រូធ្វើការសង្កេត និងជួយសិស្ស តាមការចាំបាច់។ សកម្មភាពទាំងឡាយត្រូវអនុវត្តដូចការរៀបរាប់ខាងក្រោម៖

ដាក់កង់ផ្តេក៖ រៀបដំឡាប់ក ដាក់កសេះ ចាប់ដៃ ចាប់រានក្រោយ។



- ដាក់កង់ផ្ទារ៖ រៀបដុំកណ្តាល ដាក់ជង្គង់ ឆ្វេង-ស្តាំ ចាប់ឈ្នាន់ ចាប់គម្របភក់មុខ-ក្រោយ ដាក់កង់មុខ-ក្រោយ ដាក់ជន្ទល់ ដាក់ច្រវាក់។



● ដាក់កង់បញ្ឈរ៖ ចាប់កណ្ដឹង ចាប់ដៃ ហ្វ្រាំង ស៊កស្រោមដៃ ចាប់តង្កៀប ហ្វ្រាំងមុខ-ក្រោយ វាយបង្គោលកែប ដាក់កែប និងដាក់គម្របថាស។



បញ្ជាក់៖ នៅពេលសិស្សអនុវត្ត ត្រូវសហការគ្នា ដោយបែងចែកផ្នែកនីមួយៗតាមក្រុម។

## តេស្តចំណេះដឹង៖ សំណួរសរសេរ

៣៥ នាទី

វាមានសារៈសំខាន់ ដែលសិស្សបំពេញសំណួរគ្រប់ៗគ្នា ។ សំណួរមានចំនួន ១២ សំណួរ ដែលសិស្សត្រូវឆ្លើយសំណួរទាំងអស់នោះ។ សិស្សត្រូវឆ្លើយឱ្យបានរហ័សតាមដែលអាចធ្វើបាន។

លោកគ្រូ/អ្នកគ្រូចែកទម្រង់សំណួរដល់សិស្ស (មាននៅទំព័រទី ៤២ និង៤៣ និងថតចម្លងត្រៀម ទុកជាស្រេច)។

លោកគ្រូ/អ្នកគ្រូណែនាំ ដើម្បីឱ្យសិស្សបានយល់ច្បាស់ក្នុងការបំពេញសំណួរ ជៀសវាងការលុប ឬកោស និងថែមចម្លើយ បណ្ដាលឱ្យលោកគ្រូ/អ្នកគ្រូ ពិបាកកែចម្លើយទាំងនោះ។

បន្ទាប់មកសិស្សចាប់ផ្ដើមបំពេញសំណួរ ដែលមានរយៈពេល ១៥ នាទី

## បញ្ចប់មេរៀន

១០ នាទី

គ្រូឱ្យសិស្សយកកង់ដែលបានដំឡើងរួច មកដាក់តាំងបង្ហាញ។ ឱ្យសិស្សតាមក្រុមនីមួយៗរៀបរាប់ពីសកម្មភាពសិក្សាតាមលំដាប់លំដោយ គ្រូផ្ដល់យោបល់ នឹងធ្វើការកែលម្អចំណុចអសកម្ម មួយចំនួន។

សូមប្អូនៗទៅសិក្សាស្រាវជ្រាវបន្ថែមទៀតនៅកន្លែងជាងជួសជុលកង់ រាល់ផ្នែកណាមួយ ដែលមិនច្បាស់លាស់ និងយកចំណេះដឹងពីការសិក្សាកន្លងទៅនេះ យកទៅអនុវត្តឱ្យបានល្អប្រសើរគ្រប់ៗគ្នា។

សិស្សកត់ត្រាសកម្មភាពតាមលំដាប់លំដោយខាងក្រោមនៅពេលពួកគេសង្កេតការបង្រៀនជាគំរូ និងការអនុវត្តដោយសិស្សដទៃទៀត។

ការដាក់កង់ផ្តេក: ..................................................................................................................

..................................................................................................................

..................................................................................................................។

ការដាក់កង់ផ្ងារ: ..................................................................................................................

..................................................................................................................

..................................................................................................................។

ការដាក់កង់បញ្ឈរ: ..................................................................................................................

..................................................................................................................

..................................................................................................................។



**ការវាយតម្លៃ ៖ សំណួរសរសេរ "ជំនាញជួសជុលកង់"**

ឈ្មោះ....................................ភេទ...........ថ្នាក់ទី............សាលា...................................
ស្រុក...................................ខេត្ត..............................................

១. តើកង់មានសារប្រយោជន៍អ្វីខ្លះសម្រាប់ប្រជាជនកម្ពុជា? សូមប្អូនរៀបរាប់។

..................................................................................................................................
..................................................................................................................................
..................................................................................................................................

២. តើកង់ខ្មែរមានកំណើតចាប់តាំងពីសម័យណា? (សំណួរស្រាវជ្រាវ)

..................................................................................................................................
..................................................................................................................................
..................................................................................................................................

៣. នៅពេលប្អូនប៉ះពោះវៀនកង់ តើប្អូនធ្វើសកម្មភាពជួសជុលអ្វីខ្លះ?

..................................................................................................................................
..................................................................................................................................
..................................................................................................................................

៤. តើផ្នែកមុខនៃកង់មានអ្វីខ្លះ?

..................................................................................................................................
..................................................................................................................................
..................................................................................................................................

៥. តើផ្នែកកណ្តាលនៃកង់មានអ្វីខ្លះ?

..................................................................................................................................
..................................................................................................................................
..................................................................................................................................

៦. តើផ្នែកក្រោយនៃកង់មានអ្វីខ្លះ?

..................................................................................................................................
..................................................................................................................................
..................................................................................................................................

៧. ចូរប្អូនរៀបរាប់ពីសកម្មភាពជួសជុលដុំមុខ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៨. ចូរប្អូនរៀបរាប់ពីសកម្មភាពជួសជុលដុំកណ្តាល។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៩. ចូរប្អូនរៀបរាប់ពីសកម្មភាពជួសជុលដុំក្រោយ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១០. ចូរប្អូនរៀបរាប់ពីសកម្មភាពជួសជុលដំឡាប់ក។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១១. សូមប្អូនរៀបរាប់ពីរសកម្មភាពតម្រង់ខ្នងកង់ និង ចំហៀងខ្នងកង់។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១២. ចូរប្អូនរៀបរាប់ពីសកម្មភាពជួសជុល ហ្វ្រាំងមុខ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

# ចម្លើយសំណួរសរសេរ

១- នៅក្នុងប្រទេសអភិវឌ្ឍមនុស្សប្រើប្រាស់កង់ធ្វើជាយានជំនិះសម្រាប់ជិះកំសាន្ត ប៉ុន្តែនៅក្នុងប្រទេស ក្រីក្រផ្សេងៗក្នុងពិភពលោក ដូចជាប្រទេសកម្ពុជា គេប្រើប្រាស់កង់ជាមធ្យោបាយដឹកជញ្ជូន សម្រាប់ប្រជាជនភាគច្រើន។ កង់គឺជាមធ្យោបាយមួយដើម្បីធ្វើឱ្យជីវភាពរស់នៅបានប្រសើរ ឡើង។ កង់ត្រូវបានគេប្រើប្រាស់ប្រកបដោយ សារៈសំខាន់សម្រាប់ជាមធ្យោបាយផ្សេងៗនៅក្នុង ជីវិត។ ឧទាហរណ៍ សម្រាប់ឱ្យកុមារជិះទៅសាលារៀនដែលអាច បង្កើនការសិក្សាអប់រំដល់កុមារ ក្នុងតំបន់ដាច់ស្រយាល។ ប្រើប្រាស់សម្រាប់ដឹកទឹក អុសសម្រាប់ចំអិនអាហារ ដែលអាចបង្កើនការ ថែរក្សាសុខភាព។ ប្រើប្រាស់សម្រាប់ដឹកទំនិញទៅកាន់ទីផ្សារនៅជិតៗ ដែលអាចជួយបង្កើនសេដ្ឋកិច្ចក្នុងមូលដ្ឋាន និងជាពិសេសនោះ កង់គឺជាមធ្យោបាយមួយដែលកុមារចូលចិត្តជិះជាការកំសាន្ត។

២- កង់ខ្មែរមានកំណើតចាប់តាំងពីសម័យ អាណានិគមបារាំង។

៣- ពិនិត្យមើលសំបកខាងក្រៅ លូកដៃស្ទាបច្បួតក្នុងសំបក រកមើលបន្លា ឬដែកគោលដែលមុតជាប់ នឹងសំបក បើឃើញមាន ត្រូវយកចេញ។ សប់ពោះវៀនកង់ឱ្យតឹងល្មម រួចដាក់ក្នុងកាធុនទឹក រកមើលកន្លែងមុត ឬធ្លាយ ពេលឃើញហើយ ត្រូវយកឈើចាក់ធ្មេញចុងស្រួចមកដោតចំណាំ។ ជូតពោះវៀន ឱ្យស្ងួតទឹក ត្រង់កន្លែងមុត ឬធ្លាយ ដកឈើដោតចេញ យកផ្លែរណាអារដែកមកកោសបន្តើរៗជុំវិញ កន្លែងមុតទំហំប៉ុនបំណះ យកជ័រការមកលាបស្តើងៗត្រង់កន្លែងកោស ទុកឱ្យស្ងួត បន្តិចយកបំណះមកបិទពីលើ រួចយកឬស្សី មូលមួយទៀតមកដំពីលើបំណះតិចៗឱ្យសព្វ។ ក្រោយ ពីប៉ះរួចហើយ សប់ពោះវៀនកង់នោះឱ្យតឹងល្មម យកទៅដាក់ក្នុងការធុនទឹកម្តងទៀត ត្រង់កន្លែងប៉ះរួចពិនិត្យមើលក្រែងមិនជិត។

៤- ផ្នែកមុខនៃកង់មាន

- កង់មុខ៖ សំបក ខ្នង កាំ វ៉ាល់ ដុំ ភ្លៅ គម្របភក់ ដែកកាង តង្កៀប ហ្វ្រាំងមុខ
- ជំពាស់មុខ៖ ជំពាស់មុខ ដំឡាប់កលើ-ក្រោម
- ដៃ៖ ដៃចង្កូត ស្រោមដៃ កណ្តឹង ដៃហ្វ្រាំងមុខ-ក្រោយ ខ្សែហ្វ្រាំងមុខ-ក្រោយ កសេះ ខ្ចៅកូនជញ្ជីង ក្រចាប់ដៃ

៥- ផ្នែកកណ្តាលនៃកង់មាន៖

- ទូក៖ ទូកបញ្ឈរ ទូកផ្តេកលើ ទូកផ្តេកក្រោម កែប កកែប ក្រចាប់កកែប
- ដុំកណ្តាល៖ ដុំកណ្តាល ខ្ចៅកាស់ ភ្លៅ ជង្គង់ឆ្វេង-ស្តាំ កន្លាស់ឈ្នាន់ ថាស ឈ្នាន់ឆ្វេង-ស្តាំ គម្របថាសច្រវ៉ាក់

៦- ផ្នែកក្រោយនៃកង់៖

- កង់ក្រោយ៖ សំបក ខ្នង កាំ វ៉ាល់ ដុំ ភ្លៅ ចន្ទល់ លីប
- គម្របភក់ ដែកកាង តង្កៀប ហ្វ្រាំងក្រោយ រាន ក្រចាប់រាន ឬក្រចាប់កកែប

៧- ជួសជុល៖ ត្រូវមួលរិតដំឡាប់ រ៉ងស្ពើង និងខ្ចៅរ៉ងស្ពើងម្ខាង ឱ្យងាប់ កុំឱ្យមួលចូលក្នុងបាន។ យកខ្លាញ់គោ មកលាបក្នុង ចានបន្តិច រៀបគ្រាប់ដាក់ចូលឱ្យពេញទាំងសងខាង រួចយកខ្លាញ់គោមក លាបបន្ថែមឱ្យពេញ ក្នុងចាន។ ស៊កភ្លៅចូលទៅក្នុងដុំវិញ ខាងខ្ចៅងាប់ត្រូវនៅខាងស្តាំ ឬខាងចាស មួលខ្ចៅដំឡាប់ចូលឱ្យបាន តឹង តែអាចវិលភ្លៅបាន ដាក់រ៉ងស្ពើងចូល និងមួលខ្ចៅកាស់ស្ពើង ចូលឱ្យ បានតឹង។

៨- ជួសជុល៖ ជូតក្នុងដុំ ភ្លៅ គ្រាប់ ចានឱ្យស្អាតរកមើល កន្លែងខូច បើខូចត្រង់ណាត្រូវផ្លាស់ចេញ។ បើខូចចានខាងចាសត្រូវដោះនឹងអង្គំ ពេលដាក់ចូលវិញក៏ប្រើអង្គំដែរ ត្រូវចាំថាខ្ចៅចានខាង ចាសត្រូវមួលបញ្ច្រាស។ បើខូចស្តឺដុំជាប់នឹងទូក ត្រូវយកដែកប៉ុងតួមកវាយបញ្ចុកជុំវិញត្រង់កន្លែងស្តឺខូច។ គ្រាប់ខាងចាសត្រូវ រៀបនឹងភ្លៅ គ្រាប់ខាងឆ្វេងត្រូវរៀបនឹងចាន។

៩- ជួសជុល៖ ដោះខ្ចៅទប់ ដោះខ្ចៅកាស់ ដោះរ៉ងកាស់ស្ពើង និងខ្ចៅដំឡាប់ចេញផ្នែកម្ខាង ខាងចន្ទល់ ចេញទាំងអស់ ឬយកខ្ចៅចេញទាំងអស់ពីភ្លៅ បើសិនដំឡាប់ខូច។ យកគ្រាប់ចេញពីក្នុងចានទាំង សងខាង។ ជូត ខ្ចៅរ៉ង ខ្ចៅកាស់ ដំឡាប់ គ្រាប់ ភ្លៅ ដែលបានដោះចេញទាំងអស់ និងចានក្នុងដុំឱ្យ បានស្អាតរកមើល កន្លែង ខូច បើខូចត្រង់ណា មួយត្រូវផ្លាស់ចេញ ចំពោះគ្រាប់បើមានខូចត្រូវផ្លាស់ ចេញ ទាំងអស់។ ត្រូវមួលខ្ចៅ ដំឡាប់ រ៉ងស្ពើង និងខ្ចៅកាស់ ឱ្យងាប់នៅខាងលីប កុំឱ្យមួលចូលក្នុង បាន។ យកខ្លាញ់គោ មកលាបក្នុងចានបន្តិច រៀបគ្រាប់ក្នុងចាន ឱ្យពេញទាំងសងខាង រួចយក ខ្លាញ់គោមកបៀកឱ្យពេញ ក្នុងចាន។ ស៊កភ្លៅចូលពី ខាងលីបទៅក្នុងដុំវិញ មួលខ្ចៅដំឡាប់ចូលឱ្យ តឹងតែអាចវិលភ្លៅបាន ដាក់រ៉ងស្ពើងចូល និងមួលខ្ចៅកាស់ចូលឱ្យតឹង។

១០-ជួសជុល៖ ជូតចាន ដំឡាប់ គ្រាប់ រ៉ង ខ្ចៅកាស់ឱ្យស្អាត រកមើលកន្លែងខូច បើខូចត្រង់ណាត្រូវ ផ្លាស់ចេញ។ យកខ្លាញ់គោមកលាបក្នុងចានបន្តិច រៀបគ្រាប់ឱ្យពេញ ក្នុងចានទាំងខាងលើ និង ខាងក្រោមដាក់ជំពាស់ចូលក្នុងកទូកវិញ មួលខ្ចៅដំឡាប់ចូលឱ្យតឹង តែអាចវិលជំពាស់បាន ដាក់រ៉ងធ្មេញរណាមួលខ្ចៅរ៉ងកាស់ឱ្យតឹង។

១១-តម្រង់វង្វង់ខ្នង៖ បង្វិលខ្នងកង់តិចៗឱ្យបានមួយជុំ ពិនិត្យមើលត្រង់ណាប៉ះ និងឃ្លាតពីកម្រិតខ្នាត វង្វង់។ បើត្រង់ណាប៉ះនឹងកម្រិតខ្នាតត្រូវមួលរឹតបន្ថែម តែបើត្រង់ណាឃ្លាតពីកម្រិតខ្នាតវង្វង់ត្រូវ មួលបន្ធូរ ធ្វើរបៀបនេះសាចុះសាឡើង រហូតដល់ខ្នងកង់រត់ត្រង់ស្មើដោយមិនរលក ឬពងក្រពើ។ តម្រង់ចំហៀងខ្នង៖ បង្វិលខ្នងកង់តិចៗឱ្យបានជុំ ពិនិត្យមើលត្រង់ណាប៉ះ និងឃ្លាតពីកម្រិតខ្នាត ចំហៀងខ្នង។ បើត្រង់ណាប៉ះនឹងកម្រិតខ្នាតដែលនៅខាងស្តាំដៃ ត្រូវមួលខ្ចៅក្បាលកាំនៅផ្នែកខាងស្តាំបន្ធូរបន្តិច រួចមួលខ្ចៅក្បាលកាំផ្នែកខាងឆ្វេងបន្ថែមបន្តិច ធ្វើររបៀបនេះសាចុះសាឡើង រហូត ខ្នងកង់ផ្នែកចំហៀងរត់ត្រង់ស្មើ ដោយមិនរលកឬរមួល។ ក្នុងការរិតក្បាលកាំតម្រង់វង្វង់ខ្នង និងចំហៀងខ្នង ត្រូវការសម្រួលគ្នាទាំងព្រម។

១២-ជួសជុល៖ ពិនិត្យមើលរកកន្លែងខូច បើខូចត្រង់ណា ត្រូវផ្លាស់ចេញ ដូចជាក្រចាប់ដៃ ដៃហ្វ្រាំង ស្រោមខ្សែ តង្កៀប រ៉ឺសស័រ ដុំជ័រ។

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ......................... សាលា...................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ................

| | ចំណុចត្រូវដាក់ពិន្ទុ | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| | **សង្កេតឥរិយាបថសិស្ស** | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥0=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរបាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត ......................... ស្រុក .......................សាលា ............................. ថ្នាក់ទី .......... ប្រធានបទ ...................

| ល.រ | ឈ្មោះសិស្ស | សំណេរសរសេរ | | ក៏រិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព                                        ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា                                        ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| ការអង្កេតថ្នាក់រៀន | | | | | ការវាយតម្លៃគ្រូបំណិនជីវិត |
|---|---|---|---|---|---|
| សាលារៀន | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលគ្រូបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ .......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ .....................................

# ឧបករណ៍របស់ជាងជួសជុលកង់



# តួកង់


ដៃចង្កូត
ស្រោមដៃ
ចានទ្រនាប់ក
ចង្កើរសម្រាប់ក្មេងជិះ
កែប
ដំឡាប់លើ
ចង្កើរក្រោយ
ហ្វ្រាំង
ដុំមុខ
ដំឡាប់ក្រោម
គម្រប
កងមុខ
ឈ្នាន់
ចាន
ទ្រនាប់រឹត
គ្រាប់
ច្រវាក់កង់
គ្រាប់
ជន្ទល់
សំបក
ខ្នង
កាំ

ក្រសួងកិច្ចការនារី

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN

aecid